# មជ្ឈមណ្ឌលឯកសារកម្ពុជា

*ស៊ីន ឈួន ភេទប្រុស* **I08274**

*មុខសារ គណៈឃុំស្វាយជ្រំ*

*ជួបសម្ភាសជាមួយប្អូនស្រីឈ្មោះ ស៊ីន ផែម អាយុ៦៤ឆ្នាំ*

*រស់នៅភូមិស្វាយយា ឃុំស្វាយយា ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង*

*ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៥*

*សម្ភាសដោយៈ ឡុង ដានី និង អ៊ីសា ខស្មាន*

*សរុបៈ ២៩ទំព័រ*

ឡុងដានីៈ អត់ទោសអ៊ីមានឈ្មោះអីដែរ?

ស៊ីនផែនៈ ខ្ញុំ ស៊ីនផែន គេហៅធន់ៗ

ឡុងដានីៈ ស៊ីន ផែន គេហៅធន់!

ស៊ីនផែនៈ ចាស ៗ

ឡុងដានីៈ អ៊ីសព្វថ្ងៃអាយុប៉ុន្មានហើយ?

ស៊ីនផែនៈ ខ្ញុំសព្វថ្ងៃអាយុ៦៤ចូល៦៥ឆ្នាំនឹង ៗ

ឡុងដានីៈ អ៊ីមានស្រុកកំណើតកើតជានៅណាដែរ?

ស៊ីនផែនៈ ខ្ញុំមានស្រុកកំណើតនៅនឹងតែម្តង ដីនឹងតែម្តង ៗ

ឡុងដានីៈ ទីនឹងគេហៅភូមិស្រុកអី?

ស៊ីនផែនៈ ភូមិស្វាយយា ឃុំស្វាយយា ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ៗ

ឡុងដានីៈ សព្វថ្ងៃរស់នៅភូមិឃុំដដែរនឹង?

ស៊ីនផែនៈ រស់នៅដដែល អត់មានទៅណាមកណាទេ ៗ

ឡុងដានីៈ អ៊ីមានគ្រួសារឈ្មោះអីដែរ?

ស៊ីនផែនៈ អ៊ី ទៀង ដាន់ ៗ

ឡុងដានីៈ ទៀង ដាន់ អ៊ីមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

ស៊ីនផែនៈ កូនតែពីរទេ ហើយកូនពីរនោះ ស្លាប់មួយហើយ ឥឡូវនៅតែកូនមួយ ហើយកូនមួយ នោះធ្វើទ័ពនៅអូរស្មាច់ នៅតែមួយនឹង ៗ

ឡុងដានី: ចុះគ្រួសារអ៊ំឈ្មោះដាន់?

ស៊ីនផែនៈ ស្លាប់អស់ហើយ ចាប់តាំងពីចាប់យកទៅសម្លាប់អស់ដែរ ។ មើល!ចាប់បងខ្ញុំបាន ហើយ ប្រមាណប្រហែលជាពីរទៅបីខែ គេចាប់គ្រួសារខ្ញុំទៅទៀតណា ចាប់គ្រួសារខ្ញុំទៅឆ្នាំ ៧៧ ចាប់យកទៅនឹង ។ ហើយប្អូនពៅខ្ញុំនឹងណាគេយកទៅនឹងមិនដឹងគេយកទៅមិនដឹងឆ្នាំប៉ុន្មានទេ ប្រហែលជាឆ្នាំ៧៧នឹងដែរ ប៉ុន្តែចុងខែដើមខែនឹងណាយកទៅនឹង ។

ឡុងដានី: ចុះគ្រួសារអ៊ំឈ្មោះដាន់នឹង ខ្មែរក្រហមចាប់យកទៅនៅឆ្នាំ៧៧ដែរ?

ស៊ីនផែនៈ ចាស!ឆ្នាំ៧៧ ប៉ុន្តែបងខ្ញុំនឹងគេចាប់យកទៅពីឆ្នាំណា ជំនាន់តាឈូក?

អ្នកជិតខាងៈ កាល៧៦ ចាប់មុនតាផាត ។

ស៊ីនផែនៈ នឹងហើយចាប់មុន ក្រោយតាឈូកប្រហែលជាពីរខែឬបីខែ មិនដល់ទេពីរខែនឹងហើយ យកទៅនឹងណា ។

ឡុងដានី: ចុះអ៊ំ! បើតាមអ៊ំចាំបងអ៊ំគាត់ឈ្មោះឈួននឹង កាលពីក្មេងគាត់រៀនសូត្រដល់ថ្នាក់ណាដែរ?

ស៊ីនផែនៈ រៀន សញ្ញាប័ត្រ ។

ឡុងដានី: សញ្ញាប័ត្រអីទៅ?

ស៊ីនផែនៈ សញ្ញាប័ត្រកាលនឹង ប្រហែលថ្នាក់ទី៩ ហើយទៅរៀនដល់ភ្នំពេញអីដែរនឹងណា ។

ឡុងដានី: ទៅរៀននៅភ្នំពេញ?

ស៊ីនផែនៈ ចាស!រៀនភ្នំពេញ រៀនស្វាយរៀង ទៅរៀនភ្នំពេញនឹងរៀនជាមួយតាឈូកជាមួយអាចារ្យកែវមាស ជាមួយតាជុចទៅនឹង តែដល់ពេលប្រឡងគ្រូបងខ្ញុំធ្លាក់ តែជុចនឹងជាប់គ្រូ ហើយដល់ជុចជាប់គ្រូក៏ចាប់ផ្តើមទាក់ទងគ្នាតាំងពីពេលនោះមក ហើយជាប់ចូលទៅក្នុងប្រវត្តិខ្មែរក្រហមនឹងមកណា ចូលតាំងពីកាលនឹងមកណាជាមួយតាជុច តាឈូកនឹងមកណា ជាមួយតាមូលឪបង អឺឪប្រពន្ធស៊ិនសុងនឹងហើយជាមួយគ្នាបានទាក់ទងជាមួយនឹងហើយ ពួកម៉ាក់ជាមួយគ្នាបានទាក់ទងគ្នាតាំងពីពេលនឹងមករហូតមក ។

ឡុងដានី: គាត់រៀនដល់ឆ្នាំណាទៅបានគាត់ឈប់?

ស៊ីនផែនៈ ខ្ញុំមិនដឹងឆ្នាំដែរ វាភ្លេចឆ្នាំដែរ តែសញ្ញាប័ត្រជំនាន់នឹងវាគ្រាន់ដែរណា ។

អ្នកជិតខាង : ពេលកើតខ្មែរក្រហមឆ្នាំណា ប្រហែលជា៧០ ។

ស៊ីនផែនៈ	មិនមែនទេមុន ប្រហែលជាត្រឹម៦០ ។

អ្នកជិតខាងៈ	ប្រហែលជា៦៨អី មុនរដ្ឋប្រហារ ព្រោះមុនធ្វើរដ្ឋប្រហារនឹងលន់នល់មិនធ្វើរដ្ឋប្រហារ ។

ឡុងដានីៈ	កាលនឹងអ៊ំនិយាយថាបងអ៊ំឈ្មោះឈួននឹងគាត់ប្រឡងធ្លាក់គ្រូ?

ស៊ីនផែនៈ	ចា៎ស!គ្រាន់ថាប្រឡងជាប់សញ្ញាប័ត្រទាំងអស់គ្នាជាមួយតាថុចនឹងណា ហើយដល់ពេលទៅប្រឡងគ្រូវាធ្លាក់ ហើយពូថុចនឹងគាត់ជាប់គ្រូ បងខ្ញុំធ្លាក់ទៅ ក៏បានទៅធ្វើខាងរោងចក្រជាមួយ រោងចក្របែកចានធ្វើកែវនៅភ្នំពេញទៅធ្វើនឹងទៅ ហើយបានជាមួយប្រពន្ធស៊ិនសុងទៅណាទាក់ទងគ្នា ។

ឡុងដានីៈ	អញ្ចឹងពេលដែលគាត់ប្រឡងធ្លាក់គ្រូ គាត់ឈប់រៀនទៅធ្វើការជាមួយរោងចក្រវិញ?

ស៊ីនផែនៈ	ចា៎ស!ធ្វើខាងរោងចក្រ ។

ឡុងដានីៈ	រោងចក្រនៅខាង?

ស៊ីនផែនៈ	កែវ ។

ឡុងដានីៈ	រោងចក្រកែវ បែកចានអគ្គស្នួលនោះទៅណា ។

ស៊ីនផែនៈ	ចា៎ស! ហើយអញ្ចឹងទៅបានមកមានប្រពន្ធអីនឹងណានៅស្រុកព្រះស្តេច នៅភូមិសាំងស្បានឹងទៅណា ។

ឡុងដានីៈ	គាត់ការនៅឆ្នាំណាទៅ?

ស៊ីនផែនៈ	កាលនឹងខ្ញុំមិនបានជាគិតអារឿងឆ្នាំការអីដែរណា ប៉ុន្តែវាខ្ញុំមិនដឹងឆ្នាំដែរនឹងណាវាភ្លេច មិនមែនទេកាលនឹង ការឆ្នាំរោង។...។

ឡុងដានីៈ	គាត់ការនឹងតាំងពីជំនាន់សង្គមរាស្ត្រនិយមឬក៏ការជំនាន់លន់នល់?

ស៊ីនផែនៈ	ការក្នុងជំនាន់កាលដែលចូលក្រុមសម្ងាត់ហើយ ។

ឡុងដានីៈ	បានន័យថាគាត់ការមុនថ្ងៃរដ្ឋប្រហារទម្លាក់សម្តេចសីហនុ?

ស៊ីនផែនៈ	នឹងហើយៗ មុននឹងណា ការមុននឹងណា គេមានក្រុមពួកម៉ាក់មិត្តភ័ក្តហើយ ។

ឡុងដានីៈ	គាត់ការតាំងពីនឹង ប៉ុន្តែគាត់បានចូលចលនាខ្មែរក្រហមតាំងពីជំនាន់៦០ជាង?

ស៊ីនផែនៈ	ចា៎ស!នឹងហើយ តាំងពីជំនាន់៦០ជាង ។

ឡុងដានីៈ	កាលជំនាន់គាត់ធ្វើការជាមួយតាថុច តាឈូក តាកែវមាសអីនឹងអ៊ំមានស្គាល់ទេ?

| | |
|---|---|
| ស៊ីនផែនៈ | មើល! តាថុច តាឈូកនឹងនេះផ្ទះក្បឿងនឹងបងប្អូនខ្ញុំ ត្រូវជាពូខ្ញុំទេតើ! ចាស សុទ្ធតែខ្សែខ្ញុំហើយណា គ្មានអ្នកក្រៅឯណា ។ |
| ឡុងដានីៈ | ផ្ទះគាត់នៅកន្លែងណា? |
| ស៊ីនផែនៈ | ផ្ទះក្បឿងនៅត្បូងផ្លូវនេះណា ។ |
| ឡុងដានីៈ | គាត់នៅភូមិស្វាយយានឹងដដែរ? |
| ស៊ីនផែនៈ | នៅភូមិស្វាយយាទាំងអស់ តាថុច តាឈូកៗគាត់នៅខាងដូនសរ នៅត្រង់ខាងកើតផ្សារដូនសរ នៅត្រង់វត្តតាងើន ឃុំស្វាយជ្រំ ខេត្តស្វាយរៀងដូចគ្នានឹងណា ។ |
| ឡុងដានីៈ | អញ្ចឹងត្រូវជាប់សាច់ឈាមដែររបស់អ៊ំ? |
| ស៊ីនផែនៈ | តាឈូកនឹង មិនសាច់ឈាមទេ តែគ្រាន់ថាស្គាល់គ្នាតាំងពីដើមមក ស្គាល់គ្នាតាំងពីខ្ញុំអីទាំងអស់តាឈូកនឹងណាប្រពន្ធគាត់នៅសព្វថ្ងៃនៅភ្នំពេញ ឃើញខ្ញុំស្រឡាញ់ណាស់ដូចប្អូនបងបង្កើតអញ្ចឹងណា ។ |
| ឡុងដានីៈ | យាយមន់? |
| ស៊ីនផែនៈ | នឹងហើយយាយមន់នឹង ។ |
| ឡុងដានីៈ | អ៊ំស្គាល់ផ្ទះគាត់ច្បាស់ទេ? |
| ស៊ីនផែនៈ | ថីខ្ញុំមិនស្គាល់ ខ្ញុំទៅញឹក តែឥឡូវខ្ញុំខានទៅប្រហែលបីទៅបួនឆ្នាំហើយ ។ |
| ឡុងដានីៈ | ផ្ទះគាត់ថានៅជិតពេទ្យលោកសង្ឃនឹង? |
| ស៊ីនផែនៈ | នឹងហើយនៅនឹង ហើយកូនគាត់តែបីនាក់ទេ ។ |
| ឡុងដានីៈ | កូនគាត់ឈ្មោះអី? |
| ស៊ីនផែនៈ | ចែវមួយ ពៅមួយ ហើយអាប្រុសមួយនឹងខូចណាស់មកបួសនៅវត្តតាងើននឹងណា ។ |
| ឡុងដានីៈ | អ៊ំស្គាល់អាស័យដ្ឋានផ្ទះគាត់ច្បាស់ទេ? |
| ស៊ីនផែនៈ | ស្គាល់តើ មានអីខ្ញុំទៅដល់ផ្ទះនឹងទៀត ទៅលេងណា ។ |
| ឡុងដានីៈ | ផ្ទះគាត់នៅផ្លូវលេខប៉ុន្មានដែរ? |
| ស៊ីនផែនៈ | ទៅភ្នំពេញនឹងឯង! ទៅត្រង់ស្រែអំបិលៗ ។ |
| អ្នកជិតខាងៈ | ខាងត្បូងអាលីយ៉ុង ។ |
| ឡុងដានីៈ | នៅជិតអាយ៉ុង? |
| ស៊ីនផែនៈ | មិនដឹងស្អីទេ ប៉ុន្តែខ្ញុំដឹងថានៅត្រង់ស្រែអំបិល ។ |

ឡុងដានី៖ ផ្ទះគាត់លេខប៉ុន្មាន?

ស៊ីនឆែន៖ ផ្ទះ ខ្ញុំមិនស្គាល់លេខទេណា ប៉ុន្តែផ្ទះនៅខាងត្បូងផ្លូវៗមកពីកើតអញ្ជឹងនៅខាងត្បូង ផ្លូវមកពីលិចមក ខ្ញុំដឹងតែប៉ុននឹង ។ ត្រង់ថាម៉េចៗខ្ញុំមិនដឹងទេ ផ្ទះលេខប៉ុន្មានៗខ្ញុំមិនដឹងទេ ។

ឡុងដានី៖ មុំនឹងនៅជិតអីទេ មានសណ្ឋាគារឬក៏មានស្អីទេ?

ស៊ីនឆែន៖ គ្មានទេសណ្ឋាគារ អត់មានទេ មានតែផ្ទះជួល ហើយខ្ញុំទៅខស្សាហ៍ទៅដេកលេងញឹកញាប់ ។

ឡុងដានី៖ យាយមន់ឥឡូវគាត់បែបលែងឈប់ធ្វើការហើយ?

ស៊ីនឆែន៖ ធ្វើអីគាត់ឈឺ មិនសូវទេគាត់បែបចាស់ហើយ ខ្ញុំខានឃើញគាត់បី បួនឆ្នាំហើយ តែឆ្នាំមុនៗ ខ្ញុំខស្សាហ៍ទៅណាស់ ឥឡូវខ្ញុំមិនដែលបានទៅទេណា តែដល់មិនដែលបានទៅ ឥឡូវខ្ញុំដើរទៅវាវង្វេងហើយណា ។

ឡុងដានី៖ កាលពីមុនគាត់ធ្វើការនៅក្រសួងមហាផ្ទៃ?

ស៊ីនឆែន៖ ចា៎ស!នៅនឹងឯង គាត់បានកូនគាត់ប្ដីពៅ ប្ដីថៃវ តែប្ដីថែប ឥឡូវវាយ៉ាងម៉េចទេ មានស្រីមានញីយ៉ាងម៉េចទេណា វាពិបាកដែរណា ។

ឡុងដានី៖ ចុះអ៊ំ បងអ៊ំឈ្មោះឈួននឹងណា ការហើយនឹងបន្ទាប់ពីគាត់ចូលកន្លែងសម្ងាត់ជាមួយតាឈូក តាថុចអីនឹង?

ស៊ីនឆែន៖ ចា៎ស!គាត់មុនការហើយណាជាមួយគ្នាៗឱប្រពន្ធតាសុង ជាមួយគ្នាឈូក តាថុចតាកែវមាសជាមួយគ្នានឹងណា ហើយបងអីមួយទេទៅបាត់ខ្លួនតាំងពីកាលដែរខ្ញុំជិនាន់ការពីអាយុ២២ឥឡូវវា៦៤ទៅហើយណា ខ្ញុំការ...អញភ្លេចហើយកូនតាដឹមនៅកកោះនឹងណា ដែលគាត់អ្នកទាក់ទងនឹងបងនឹងណាមួយដែរ តែឥឡូវកាលនឹងគាត់ចេញទៅលាកាលដែលមកការអញនឹងណា ហើយគាត់លាអញ អឺអញទៅការឱផាតនឹងណា ហើយគាត់លាថា ប្អូនឯងឲ្យអង្ករបងមួយតៅទៅ ហើយដល់ការប្អូនឯងបងមកការ ហើយដល់ពេលនោះទៅៗបាត់ខ្លួនតាំងពីកាលនឹងមកហើយ មិនជួបគ្នា ។ ហើយបងខ្ញុំនៅធ្វើនឹងទៅ ។

ឡុងដានី៖ កាលនឹងម៉េចបានអ៊ំដឹងថា បងអ៊ំគាត់ធ្វើការជាមួយតាឈូក ជាមួយតាថុច តាកែវមាស ជាមួយឪពុកក្មេករបស់ស៊ីនសុង គាត់ធ្វើការសម្ងាត់នឹង តាំងពី?

ស៊ីនឆែន៖ ចុះខ្ញុំដឹងៗដែរ ព្រោះខ្ញុំគេទាក់ទងមកដែរ ខ្ញុំចេះដែរ ។

ឡុងដានី៖ គេទាក់ទងមកដែរ?

ស៊ីនផែន៖ ចាស! ព្រោះកាលជំនាន់នឹងខ្ញុំសម្ងាត់របស់ខ្ញុំដែរ ខ្ញុំដូចវាថាដើងមួយ ដៃមួយនឹង ណា វាមិនមែននេះណា បងខ្ញុំក៏មិនលាក់ខ្ញុំ ហើយខ្ញុំក៏មិនលាក់បងខ្ញុំដែរ ក្រុមសម្ងាត់ទាំងអស់គ្នាណា ។

ឡុងដានី៖ កាលនឹងអ៊ំស្គាល់តាកែវមាស តាឈូក តាថុច ឪពុកក្មេកស៊ីនសុងច្បាស់តែម្តង?

ស៊ីនផែន៖ ចាស!

ឡុងដានី៖ គាត់ធ្លាប់មកធ្វើការទាក់ទងមកដល់ស្រុកភូមិជាមួយមីង?

ស៊ីនផែន៖ គាត់មិនដែលមកទេតានឹងគាត់មិនដែរមកទេ តែបងខ្ញុំៗមកនិយាយព្រោះតែៗខ្ញុំវាមិនដឹងថា តាមុយ តាហ៊ុយមិនដឹង ឪបងប្អូនខ្ញុំទៅស្គាល់មួយគគោក ។ តែខ្ញុំមិនបានទៅឃើញមុខគាត់ទេតាហ៊ុយ តែខ្ញុំស្គាល់តាឈូក ហើយពូកែវមាស ត្រូវជាបងតាថុច ។ ប្រវត្តិគាត់មុនដំបូងគាត់ទៅនៅផ្សារ គាត់នៅទួលគោក ។

ឡុងដានី៖ ពេលដែលបងរបស់អ៊ំឈ្មោះឈួន គាត់រៀបការរួចគាត់ទៅនៅឯណាទៅ?

ស៊ីនផែន៖ គាត់ទៅនៅផ្ទះប្រពន្ធ ប៉ុន្តែយើងទៅមកៗនឹងណា ដូចថាទៅនោះផងទៅនេះផង ចល័តទៅមកៗអញ្ចឹងណា ។

ឡុងដានី៖ អញ្ចឹងពេលគាត់ការរួច គាត់នៅតាំងចា នៅព្រះស្តេចអញ្ចឹងទៅណា?

ស៊ីនផែន៖ ចាស!នៅតាំងចា នៅនឹងទៅ ។

ឡុងដានី៖ ប៉ុន្តែការងារសម្ងាត់របស់គាត់ដែលទាក់ទងជាមួយតាកែវមាស តាថុចនឹង តាឈូក នឹងគាត់នៅធ្វើការដដែល?

ស៊ីនផែន៖ ចាស!នៅដដែល នៅធ្វើដដែលទៅមកៗដឹងម៉ោងនឹងអញ្ចឹង ប្រហែលជាខ្ញុំ គ្រួសារខ្ញុំទៅនឹងអញ្ចឹងទៅ គ្រួសារខ្ញុំចូលទៅក្នុងនឹងដែរនឹងណា តាមខ្សែរយៈបងប្អូនទៅតែមួយដែរនឹងណា ។

ឡុងដានី៖ ចុះកាលនឹងអ៊ំដឹងថា គាត់ក្តាប់នៅខាងណាដែរ?

ស៊ីនផែន៖ ក្តាប់នៅខាងព្រៃប្រទល់យួន ។

ឡុងដានី៖ គេហៅកន្លែងនឹងជាកន្លែងអីដែរ?

ស៊ីនផែន៖ គេហៅស្ទឺ...នៅពាមប្រពា ។

ឡុងដានី៖ នៅពាមប្រពានឹង?

ស៊ីនផែន៖ ចាស!ពាមផ្ទា នៅត្បូងក្រសាំងសាប ។

ឡុងដានី៖ តែគាត់នៅធ្វើការខាងនឹងខាងកាន់ទ័ពឬខាងស៊ីវិលអីគេដែរ?

ស៊ីនផែន៖ ខ្ញុំក៏មិនដឹងពីគេអញ្ចឹងដែរណា គេហៅថាមេទ័ព ដឹកនាំគេចុះឡើងៗអញ្ចឹងទៅណា ។ ហើយដល់ពេលក្រោយមកបានរកបាញ់អញ្ចឹងទៅណា បានរត់បែកគ្នាអស់ហើយ ក្រោយពីបាញ់រត់បែកគ្នាអស់ហើយ ទើបរត់រកគ្នាវិញឃើញ ប្រមូលគ្នាឃើញ ។

ឡុងដានី៖ ចុះពេលអ៊ំធ្វើការសម្ងាត់តាំងពីជំនាន់ មុនគាត់ការតាំងពីជំនាន់សម្តេចមកម្ល៉េះ កាលនឹងគាត់មានត្រូវបានរដ្ឋអំណាចសង្គមនិយមចាប់ខ្លួនទេ?

ស៊ីនផែន៖ អត់មានទេ ស្ងាត់ល្អណាស់ គ្មានដែលពីណាដឹងទេ គ្មានពីណាព្ទុទេ ដឹងតែត្រូសារទេណាៗ ។

អ្នកជិតខាង៖ ដឹងតែប៉ូលីស តាថុច គាត់បង្រៀននៅសាលាវត្តព្រីង គេមករកតាមចាប់គាត់រក រួចលើកទាំងលងបាញ់ ។

ស៊ីនផែន៖ គាត់ថាគាត់ធ្វើគ្រូពូថុចនឹងណាធ្វើគ្រូ វារៀងបែកការ គាត់ទៅរកៗទៅណា គាត់ទៅព្រៃបាត់ទៅណា ទាល់តែជុំគ្នានឹងណាបានត្រឡប់មកវិញណា ។

ឡុងដានី៖ ចុះអ៊ំគាត់ធ្វើការនៅពាមជ្វានឹងរហូតដល់បែកឆ្នាំ៧៥ ឬក៏គាត់ផ្លាស់ទៅណាទៀត?

ស៊ីនផែន៖ ផ្លាស់ទៅណានៅធ្វើនឹងតែម្តង អ៊ីគាត់មកនៅបាភ្នំៗពេលបែកឆ្នាំ៧៥ហើយ ។

ឡុងដានី៖ អញ្ចឹងពេលបែក៧៥ហើយ គាត់មកនៅបាភ្នំវិញ?

ស៊ីនផែន៖ ចា៎ស!ចុះគាត់ធ្វើមេទ័ព ។

ឡុងដានី៖ បាភ្នំ កាលនឹងគាត់ធ្វើមេទ័ពនឹង ធ្វើខាងអីមានតួនាទីរបស់គាត់?

ស៊ីនផែន៖ តួនាទីខាងមេទ័ព មិនដឹងខាងអីទេ ។

ឡុងដានី៖ មេទ័ពមានច្រើន មានមេទ័ពខាងស្រុក ទ័ពតំបន់ទ័ព?

ស៊ីនផែន៖ នឹងហើយ មេទ័ពខាងតំបន់ៗ ។

ឡុងដានី៖ អ៊ំដែលព្ទុឈ្មោះច័ន្ទចក្រីទេ?

ស៊ីនផែន៖ ខ្ញុំព្ទុ តែខ្ញុំមិនដែលឃើញមុខទេ តែបងខ្ញុំនិយាយប្រាប់ ។

ឡុងដានី៖ គាត់និយាយថាម៉េច?

ស៊ីនផែន៖ ថា«ច័ន្ទចក្រីមកនៅជាមួយគ្នាដែរ»ក្រោយមក ។

អ៊ីសាខស្នាន៖ ស្លាប់ហើយដែរ?

ស៊ីនផែន៖ ស្លាប់ហើយ គេចាប់អស់រលីងតាំងពីអើយ មួយជំនាន់បងខ្ញុំនោះ គេចាប់អស់ហើយមាននៅឯណា ។ ចាប់តាឈូកហើយ បែបចាប់ចក្រីមុនមិនដឹងចាប់តាឈូក

មុនមិនដឹងទេ ហើយដល់ដឹងខ្ញុំដូចជាចាប់ថ្ងៃនឹងអញ្ចឹង ព័ត៌មានមកដល់កន្លែងគ្រួសារខ្ញុំភ្លាម គ្រួសារខ្ញុំនឹងអ្នកដែលនៅកន្លែងនឹងក្រៀមក្រំរហូតទល់តែគេចាប់បងខ្ញុំទៅទៀតក៏ខ្ញុំដឹងទៀត ។

អ៊ីសាខស្ពាន: អញ្ចឹងអ៊ំនៅចាំបងអ៊ំនឹងគេចាប់ទៅនៅឆ្នាំណា បន្ទាប់ពីគេចាប់តាឈូក?

ស៊ីនផែន: ពី មើល!ចាប់តាឈូកមិនដឹង ខ្ញុំដល់ភ្លេចពេល ។

អ្នកជិតខាង: កាលនឹង បើចាប់ៗ៧៦ព្រោះតាប្ដីយាយចាប់នៅឆ្នាំ១៩៧៧ហើយ ។

ស៊ីនផែន: ប្រហែលជា៧៦មើលទៅ ។

អ្នកជិតខាង: វាមិនដឹងខែណា អីណាដែរ មិនដឹងដែរ កាលនឹងខ្ញុំនៅតូចៗដែរ ។

ស៊ីនផែន: មើល!ឯងមានចាំបាន ចាប់តាស៊ឹមមានដឹងគេចាប់តាស៊ឹមទេ?

អ្នកជិតខាង: ចាប់តាស៊ឹម ឃើញចាប់មុនពូតើ!

ស៊ីនផែន: មុនពូមែន! ប៉ុន្តែចាប់នៅខែណា?

អ្នកជិតខាង: ទេ!គ្មានអ្នកណាដឹងទេ កាលនឹងខ្ញុំនៅតូចដែរ ។

ស៊ីនផែន: មើល!ពូស៊ឹមៗមុនតាថុចឬទៅក្រោយតាថុច?

អ្នកជិតខាង: ទៅក្រោយ តាថុចចាប់មុន ។

ស៊ីនផែន: ចាប់បងសាមិតហើយ គេចាប់តាថុច ទេមិនមែនទេ ចាប់ពូស៊ឹមទេ ហើយចាប់ពូស៊ឹមហើយបានពូថុចនឹងទៅក្រោយ ពូថុចនឹងទៅបារិកនោះទៅចន្ទ្រានោះ ទៅនោះគេចាប់នៅនោះ ។

អ្នកជិតខាង: តាថុច ពួកម៉ាក់គាត់វៀតណាមវាយបែកហើយ កាលឆ្នាំ១៩៧៩បែកហើយ ពួកម៉ាក់គាត់វៀតណាមមកបន្ទោសប្រពន្ធគាត់ចង់រាប់ហើយ បបួលគាត់ឲ្យទៅ ហើយគាត់មិនទៅ តាថុចមិនទៅវៀតណាម បើទៅវៀតណាមរស់បាត់ហើយ ។

ឡុងដានី: អ៊ំ បងអ៊ំដែលត្រូវគេចាប់ បន្ទាប់ពីគេចាប់តាឈូក ច័ន្ទចក្រីនឹង រយៈពេលប៉ុន្មានបានគេមកចាប់បងអ៊ំទៀត?

ស៊ីនផែន: ប្រហែលជាពីរខែ ។

ឡុងដានី: កាលនឹងគេចាប់បងរបស់អ៊ំនឹងគេចាប់នៅកន្លែងណា?

ស៊ីនផែន: ចាប់នៅបាក្នុំនឹង វាប់នៅនឹងតែម្ដង ។

ឡុងដានី: កាលនឹងហេតុអីបានអ៊ំដឹង?

ស៊ីនឆែនៈ ជី!មិនដឹងបើខ្សែរយៈទៅមក ចល័តទៅមក ខ្សែរយៈគ្រួសារខ្ញុំទៅមកផ្ញើនេះរាល់តែថ្ងៃដែរ នៅនឹងដែរ ។ ហើយដល់អញ្ចឹងគាត់មកចុះមក សុទ្ធតែគ្រួសារចុះមកមាននេះណា នៅកន្លែងនឹងសុទ្ធតែគ្រួសារ បងប្អូនខ្ញុំមួយគគោកនៅនឹង ។

ឡុងដានីៈ កាលនឹងប្រពន្ធកូនគាត់យ៉ាងម៉េចដែរ ពេលដែលគេចាប់បងអ៊ំ?

ស៊ីនឆែនៈ ប្រពន្ធកូន ហើយពេលបែកហើយគេបញ្ជូនទៅលិចដែរ បញ្ជូនទៅថាទៅងាប់អស់ហើយ ចេះមានអីបានរស់មកវិញ ។

អ៊ុំសាខស្នានៈ បញ្ជូនទៅលិច ថាទៅណាដែរ?

ស៊ីនឆែនៈ បញ្ជូនទៅណានោះ ទៅពោធិសាត់ ទៅណាស្រុកណានោះនឹង បញ្ជូនទៅថាទៅទាំងអស់គ្នា កូនមកវិញនៅតែស្បែកហើយនឹងឆ្អឹងដូចនេះអញ្ចឹងជិតងាប់ហើយ ។

ឡុងដានីៈ កាលគេចាប់ទៅនឹងអ្នកណាដែលឃើញព្រឹត្តិការណ៍ដែលគេចាប់បងអ៊ំទៅនោះ?

ស៊ីនឆែនៈ អឺ!ដែលគេចាប់ទៅនឹងខ្ញុំមិនដឹងអ្នកណាឃើញមិនឃើញទេណា ប៉ុន្តែគ្រាន់តែគេមានលិខិតផ្ញើមកៗអញ្ចឹងនឹងណា លិខិតផ្ញើមកប្រាប់ថាគេចាប់ហើយ ថ្ងៃនេះថ្ងៃនោះអញ្ចឹងណា ដឹងថាគេចាប់ ។ ប៉ុន្តែដឹងថាពីណាៗ ខ្ញុំក៏មិនចាប់អារម្មណ៍ចំណាំទុកថាត្រង់នឹងដែរ ខ្ញុំអត់មានចាំទេ ។

ឡុងដានីៈ កាលនឹងដូចថាប្រពន្ធកូនគាត់អី ពេលដែលគេចាប់ទៅនឹងប្រពន្ធកូនគាត់នៅកន្លែង?

ស៊ីនឆែនៈ នៅកន្លែងនឹង នៅផ្ទះសព្វថ្ងៃ ។

ឡុងដានីៈ បាទ!ប៉ុន្តែ ពេលដែលគេចាប់ប្តីគាត់ទៅនឹង ប្រពន្ធកូននៅជាមួយគាត់ដែរ ឬក៏នៅផ្សេងគ្នា?

ស៊ីនឆែនៈ គាត់នៅនេះទេ នៅឯត្រង់ព្រែកក្តាម ទេនៅខាងកើតក្រសាំងចារត្រង់ខាងត្បូងត្រពែក ខាងត្បូងត្រើយខាងលិច ស្អីត្តូក្រសាំងចារ នៅខាងកើតក្រសាំងចារ នៅក្នុងមាត់ទន្លេ គេហៅស្អីទេ គេចាប់ៗតាំងពីនឹងទៅ ហៅស្អីទេបាម៉ាកុហៅចាមព្រោះវានៅនឹងឯង ។

ឡុងដានីៈ បន្ទាប់ពីគេចាប់បងអ៊ំទៅនឹង ក្រោយមកទៀតមានដែលឮដំណឹងអីពីគាត់ ឬក៏យ៉ាងម៉េចទៀតដែរ?

ស៊ីនឆែនៈ អត់មានទេ បាត់ឈឹងសូន្យតែម្តង ដឹងថាយកទៅអត់មានតែម្តង គេយកទៅសម្លាប់ ប៉ុន្តែបើគេចាប់យកមកៗភ្នំឈើកាច់ គេយកមកនឹង ។

អ៊ុំសាខស្នានៈ ស្អីគេយកមកភ្នំឈើកាច់ គេយកទៅនឹង?

ស៊ីនផែនៈ ចាស!គេយកមកភ្នំឈើកាប់ ។

អ៊ីសាខស្នានៈ កន្លែងនឹងជាកន្លែងស្អីគេ?

ស៊ីនផែនៈ កន្លែងគុកមិនដឹង ស្អីមិនដឹង ។ ចាប់យកមកទុកនៅនឹង តែបើស្លាប់ៗនៅនឹងនៅភ្នំឈើកាប់ ។

ឡុងដានីៈ ចុះសព្វថ្ងៃអ៊ំមាននៅសេសសល់រូបថត ឯកសារអីពីបងអ៊ំឈ្មោះឈួនដែរឬអត់?

ស៊ីនផែនៈ អត់មានទេ! បាត់អស់រលីងតែម្តង រូបថតមានតែឥឡូវបាត់អស់ នៅតែរូបថតប្អូនពៅមួយ ។

ឡុងដានីៈ អញ្ចឹងបើគិតមកដល់សព្វថ្ងៃ បើតាមអ៊ំវិញ អ៊ំគិតថាគាត់នៅមានជីវិតរស់នៅឬអត់ ទេក្នុងចិត្តអ៊ំ?

ស៊ីនផែនៈ អត់មានទេៗ សម្លាប់អស់ហើយ គ្មាននៅសល់ទេ ចាប់យកទៅនោះគ្មានបានប៉ុន្មានឆ្នាំទេ បើខំណាស់បានតែកន្លះខែ បែបសម្លាប់ចោលអស់ហើយ ។ តែគ្រួសារខ្ញុំចាប់យកទៅមិនបានមួយខែផង យកមកសម្លាប់ចោល ។ ប្អូនខ្ញុំកាលពីដើមទៅនៅធ្វើពេទ្យខាងគេហៅពេទ្យលុកសាំងពីដើមនឹងណា នៅខាងវត្តនិរោធ៍ៗ ហើយដល់ពេលអញ្ចឹងទៅឥឡូវមិនដឹងយកទៅណាបាត់ឈឹងទៀត ។

អ៊ីសាខស្នានៈ ប្អូនឈ្មោះអី?

ស៊ីនផែនៈ ប្អូនស៊ិន ឈូក ប្អូនពៅ ។

អ៊ីសាខស្នានៈ ប្រុសឬស្រី?

ស៊ីនផែនៈ ប្រុស ។

ឡុងដានីៈ កាលនឹងគេចាប់យកទៅ កាលនឹងបងអ៊ំឈ្មោះឈួនហើយនឹងប្អូនពៅឈ្មោះឈូកហើយពីណាទៀត ចាប់ទៅ?

ស៊ីនផែនៈ ចាប់ទៅៗ នែក!ប្អូន ស៊ីនឈូកប្អូនពៅ ហើយគ្រួសារខ្ញុំនឹង ឈៀនដាន់ក៏គេចាប់ដែរ ។

អ្នកជិតខាងៈ ប្តីគាត់គេចាប់យកទៅនៅឆ្នាំ១៩៧៧ យកទៅវត្តធ្លោក យកទៅ...។

អ៊ីសាខស្នានៈ កាលនឹងប្តីអ៊ំខុសអីទៅបានជាគេចាប់យកទៅវត្តធ្លោក?

ស៊ីនផែនៈ អឺ!ខ្ញុំមិនដឹងដែរ ចាប់តាមខ្សែបណ្តាញអញ្ចឹងម្តង ដូចថាចាប់មេៗហើយចាប់កូនៗ ចាប់រហូតតែម្តងមិនដឹងជាយ៉ាងម៉េចទេ ក្រោយមកបានគេសម្លាប់ចោល មិនដឹងយ៉ាងម៉េចទេ ខ្ញុំមិនដឹងដែរ ។

អ៊ីសាខស្ងួនៈ ពេលដែលគេចាប់គាត់ ហើយដូចលោកអីអ៊ី គេអត់មានគាមដានឲ្យពីណាមកស៊ើប សួរអីយ៉ាងម៉េចទេ?

ស៊ីនផែនៈ គេមិនជាគាមដានអីទេ បែបជាគេប្រើយើងឲ្យធ្វើ បើមិនធ្វើយើងមិនហ៊ានប្រកែក មិនហ៊ានប្រណាំងអីទេ គេរុញឲ្យទៅណាទៅនឹង១ ។

អ៊ីសាខស្ងួនៈ មានពីណាមកសួរនាំទេ សួររឿងប្តី?

ស៊ីនផែនៈ គេមិនសួរទេ គេអត់មានសួរទេ គ្រាន់តែគេប្រើយើងឲ្យធ្វើណា៎ ។ ហើយប្រើអញ្ចឹង គេឲ្យបាយប៉ុន្មានយើងស៊ីប៉ុននឹង អត់ហ៊ានម៉ាត់ហ៊ានកទេ ខ្ញុំមិនហ៊ានទេ ។ ដេកភ័យ បុណ្យឲ្យតែបងប្អូនមកជួយរស់បានមានជីវិតបានរស់នៅប៉ុននឹង សំណាងណាស់ នៅ មានថ្ងៃដែលគេបញ្ជូនឲ្យទៅរកគ្រួសារដូចគេថាអញ្ចឹងណា ខ្ញុំបានវៀតណាមមកជួយ បានបាក់បែកគ្នាអស់ទៅ បានរស់រានមានជីវិតមកនៅសព្វថ្ងៃនឹង ខ្ញុំមិនភ្លេចគុណទេ ។

ឡុងដានីៈ កាលនឹងគ្រួសារអ៊ំ គាត់ធ្វើមេឃុំណាទៅ?

ស៊ីនផែនៈ មេឃុំស្រុកស្វាយយានេះ ។

ឡុងដានីៈ គាត់ធ្វើតាំងពីឆ្នាំណាដល់ឆ្នាំណា?

អ្នកជិតខាងៈ គាត់តាំងពីជំនាន់យើងតស៊ូជំនាន់លន់នល់អីនឹង គាត់មេឃុំតាំងពីនឹងមក ទម្រាំលន់ នល់បែកហើយ បានគេមកចាប់នៅឆ្នាំ១៩៧៧នឹង ។

ឡុងដានីៈ ចុះអ៊ំកាលពីចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩នឹង គេឲ្យអ៊ំធ្វើការងារអីខ្លះទៅ?

ស៊ីនផែនៈ ខ្ញុំកាលនឹងវានេះដែរ ទើបក្រោយមកបានគេប្រើណាឲ្យធ្វើនេះធ្វើនោះអីអញ្ចឹង ឲ្យ ទៅជីកប្រឡាយ ត្រពាំង ធ្វើស្រែ ទៅស្ទូងទៅដកអី ខ្ញុំទៅធ្វើតែរហូត គ្មានដែល ទំនេរទេ ។

ឡុងដានីៈ ដូចថាកាលនឹងអ៊ំត្រូវជាប្រពន្ធរបស់គណៈឃុំអីអញ្ចឹង អ៊ំទៅធ្វើការជាមួយប្រជាជន ធម្មតាដែរ?

ស៊ីនផែនៈ ចា៎ស!ធ្វើជាមួយធម្មតាដែរ ខ្ញុំគ្មានដែលនៅផ្ទះទេ ខ្ញុំទៅខ្ញុំស្ទូងទៅដកអីទាំងអស់មិន ដែលខានមួយពេលទេ ប៉ុន្តែគ្រួសារខ្ញុំធ្វើគណៈឃុំមែនពិតតែខ្ញុំមិនដែលនៅផ្ទះទេ មិន ដែលនៅទេ ខ្ញុំទៅធ្វើស្ទូងដកអី ខ្ញុំទៅធ្វើរហូត ។

ឡុងដានីៈ ចុះដូចថាការហូបចុកអី យើងហូបដូចប្រជាជនឬមួយយ៉ាងម៉េច?

ស៊ីនផែនៈ ហូបដូចធម្មតាជាមួយគេជាមួយឯង ចុះបាយរួមបាយអីនឹងណា ខ្ញុំហូបដូចគេអញ្ចឹង គ្មាននេះឯណា មានទៅឯងស៊ីលើសគេអី គ្មានអុងអាត់អីខាងធ្វើជំទាវធ្វើលោកស្រី

ឯណាក៏នេះអី ខ្ញុំដូចថាសាមញ្ញទៅ គេក៏ធ្វើធំៗតែគេទៅ ហើយយើងធ្វើរាស្ត្រ សាមញ្ញប្រពន្ធនឹងណា ខ្ញុំមិនដែលទៅធ្វើស្អី ដែលគេស្អប់គេខ្ពើមនោះទេ ។

ឡុងដានី: អ៊ីខ្ញុំសុំសួរបកទៅក្រោយបន្តិចកាលពីមុនរបបប៉ុលពត កាលពីកំឡុងឆ្នាំ៧០ ៗ នៅស្រុកភូមិយើងនឹងខាងទ័ពរំដោះគ្រប់គ្រងប្តូលន់នល់គ្រប់គ្រង ពេលរដ្ឋប្រហារទម្លាក់សម្តេចហើយ?

ស៊ីនឆែនៈ ក្រោយពីនឹង កងទ័ពរំដោះអ្នកគ្រប់គ្រង ។

ឡុងដានីៈ កងទ័ពរំដោះអ្នកគ្រប់គ្រង ។ចុះអ៊ំពេលដែលកងទ័ពរំដោះគ្រប់គ្រងពីឆ្នាំ៧០ មកអញ្ចឹង ប្រជាជននៅតាមស្រុកភូមិយើងនឹងយ៉ាងម៉េចដែរ?

ស៊ីនឆែនៈ អត់មានម៉េចទេ ធម្មតា ។

ឡុងដានីៈ ដូចថាពេលនឹងគេចាប់ផ្តើមដូចថាគេរៀបចំប្រជាជនឲ្យធ្វើការងារអីយ៉ាងម៉េច ដូចថាគេរៀបចំជាក្រុម ជាសហករណ៍យ៉ាងម៉េច?

ស៊ីនឆែនៈ ក្រុមៗ សហករណ៍អញ្ចឹងដែរ តែដូចថាកងទ័ពមកក៏គេមិនដែលទៅធ្វើអីយើងៗក៏មិនដែលទៅធ្វើអីគេដែរ មានតែឲ្យបាយទឹកគេហូបទៅណា បើមានមកតាមផ្ទះនឹងយើងក៏ផ្គត់ផ្គង់គេទៅណា មានតាំងពីហានូយអីៗមកនៅផ្ទះខ្ញុំពេញៗផ្ទះ ពួកហានូយហើយអស់ចេះខ្មែរបន្តិចសោះមកនៅនឹងមកនៅផ្ទះខ្ញុំមកដេកពេញព្រៃរង្គើរ ហើយឲ្យដាំស្លឲ្យយកទៅឲ្យហូបទៅណា ពួកខ្ញុំដាំស្លឲ្យគេហូបអញ្ចឹងគេសុទ្ធតែឲ្យយើងហូប មុននឹងហើយសហការជាមួយពួករំដោះ វាយទាហានអាមេរិកកាំង លន់នល់ ។

ឡុងដានីៈ ចុះដូចថាពេលនឹងមានខាងកងទ័ពរំដោះ មានខាងពួកយៀកកុងគេចុះមកតាមស្រុក ភូមិចុះប្រជាជនធ្វើការងារ ធ្វើស្រែចម្ការនៅធ្វើការដូចធម្មតា ដូចថាធ្វើស្រែខ្លួនយើងយកមកហូបខ្លួនយើង ឬក៏ធ្វើការជារួមអីយ៉ាងម៉េចៗ?

ស៊ីនឆែនៈ យើងធ្វើរបស់យើង ធ្វើប្រវាស់ដៃ ដូចថាធ្វើរួមអញ្ចឹងទៅៗ ហើយដល់ពេលអញ្ចឹងយើងធ្វើហូបតាមផ្ទះទៅណា ហើយបើគេមកអញ្ចឹងយើងជួយបាយម្ហូបបន្តិចបន្តួចទៅណា ។

អ៊ីសាខស្ថានៈ លោកអ៊ំប្រវាស់ដៃនឹងធ្វើយ៉ាងម៉េចទៅ ខុសពីឥឡូវយ៉ាងម៉េចទៅ?

ស៊ីនឆែនៈ ប្រវាស់ដៃនឹង ធ្វើដូចថាខ្ញុំអញ្ចឹងស្រែខ្ញុំទៅ ស្រែគេដោយឡែកទៅ ស្រែខ្ញុំដោយឡែក ទៅចូលគ្នាស្ទូងរួមគ្នាតែម្តងទៅណា ស្ទូងរួមគ្នាដូចថាមួយថ្ងៃ ពីរបីថ្ងៃផ្ទះខ្ញុំទៅពីរបីថ្ងៃផ្ទះក្មួយខ្ញុំទៅអញ្ចឹងទៅណា ។

អ៊ីសាខស្នានៈ ចុះពេលបានផល?

ស៊ីនផែនៈ បាលផលច្រូតយកតាមផ្ទះទៅណា ស្រែយើងច្រូតយករបស់យើងទៅណា ជួយគ្នាច្រូត ៗ តែដល់ក្រោយមកអត់ទេ បាយរួមតែម្តងបាយរួមធ្វើស្រែយកទាំងអស់តែម្តង ។

អ៊ីសាខស្នានៈ ចុះអំពីពេលដែលធ្វើក្រុមប្រវាស់ដៃ អញ្ចឹងអ្នកដែលមានដីតិចទៅធ្វើឲ្យអ្នកដែលមានដីច្រើនគេសុខចិត្តទេ?

ស៊ីនផែនៈ ទំនាស់គ្នាដែរ ។

អ្នកជិតខាងៈ ទំនាស់ដែរ តែតាមការគ្រប់គ្រងមេភូមិ មេអីគេនឹងណា ជាសហករណ៍ គេដដឹកឲ្យធ្វើអញ្ចឹងដើម្បីជួយកម្លាំងដែលជាកម្លាំងធ្វើទ័ពអីដែលការពារនៅខាងមុខនោះ គេឲ្យយើងធ្វើអញ្ចឹង ដើម្បីយកកម្លាំងទៅធ្វើទ័ពធ្វើអី ទប់ទល់សជាមួយលន់នល់កាលនោះ ។

អ៊ីសាខស្នានៈ អញ្ចឹងដូចថាបញ្ហាកើតឡើងដូចថាប្រណែនគ្នានឹងមានដែរ នៅតាមក្រុមនីមួយៗ?

ស៊ីនផែនៈ មានៗ មិនអត់ទេ ។

អ្នកជិតខាងៈ មានដែរ តែធ្វើទៅមិនរួចពីមេក្រុម ហើយនិងមេភូមិ ។

អ៊ីសាខស្នានៈ មេក្រុម មេភូមិគេធ្វើយ៉ាងម៉េច នៅពេលមានទំនាស់កើតឡើង?

អ្នកជិតខាងៈ គេដោះស្រាយមិនឲ្យយើងទំនាស់គ្នា កុំឲ្យឈ្លោះគ្នា ដើម្បីជួយអ្នកដែលគេមានប្តីធ្វើទាហានអីអញ្ចឹងណាគ្មានអ្នកណាជួយ ។

អ៊ីសាខស្នានៈ ទំនាស់គ្នានឹងដោយសារតែអ្នកមានដីតិចទៅធ្វើឲ្យអ្នកមានដីច្រើន ឬក៏មានបញ្ហាអីកើតឡើងផ្សេងទៀត?

អ្នកជិតខាងៈ ដោយសារតែអ្នកមានដីតិចទៅធ្វើឲ្យអ្នកច្រើន ។

ស៊ីនផែនៈ អានេះទំនាស់ដែរ ប៉ុន្តែថាខ្លះដែលអ្នកមានដីតិចនឹង វាអត់មានមនុស្សៗវាធ្វើជាមួយ គេមានមនុស្សច្រើនអញ្ចឹងទៅណា គេមានគ្នាច្រើនទៅហើយ ម៉្លេះហើយគេរួមគ្នាទៅក៏វាមិនសូវជាអីប៉ុន្មានដែរ ។

អ៊ីសាខស្នានៈ ក្នុងមួយក្រុមមានប៉ុន្មានគ្រួសារ?

ស៊ីនផែនៈ ៧ទៅ៨គ្រួសារ ។

អ៊ីសាខស្នានៈ ៧ទៅ៨គ្រួសារក្នុងមួយក្រុម ។

ស៊ីនផែនៈ ចា៎ស!

អ៊ីសាខស្ថានៈ លោកអ៊ំខ្ញុំសុំសួរមួយទៀត ដូចអ្នកដែលអត់មានដី ធ្វើយ៉ាងម៉េចទៅ ដួយគេចូលទៅក្នុងក្រុមនឹងដែរឬអត់ ដូចសព្វថ្ងៃនឹងអញ្ចឹងអ្នកខ្លះអត់មានដីរកស៊ី ទៅប្រកបមុខរបរផ្សេងធ្វើជាង លក់ដូរ ឬធ្វើការងារផ្សេងដែល អត់ត្រូវមានដី ។ អញ្ចឹងអ្នកនឹងត្រូវធ្វើយ៉ាងម៉េច?

ស៊ីនឆែនៈ អឺ!បើដូចពីកាលដែលថាមុននឹង មិនមែនថាអ្នកដែលគ្មានទេសុទ្ធតែមាន តែទោះបីមានក៏វាមិនច្រើនដូចគេអ្នកមានៗ បើអ្នកណាគេគ្រាន់ទៅដីគេច្រើនទៅណា ហើយដូចអ្នកខ្ញុំអញ្ចឹងទៅណាក៏ដីតិច មិនមែនថាគ្មានអ្នកណាដែលគ្មានទេណាមានកាលនោះតែដល់ក្រោយមកគេចែកដីៗដកដីចេញទៅ ។

អ៊ីសាខស្ថានៈ បើអ្នកណាមានដីច្រើនគេដកយ៉ាងម៉េច?

ស៊ីនឆែនៈ មានដីច្រើនអញ្ចឹងគេដកដីយកមកឲ្យអ្នកដែលគ្មាន សុទ្ធតែចែក ។

អ្នកជិតខាងៈ មេភូមិ មេឃុំ គេអាចដកចំណែកដីបាន ។

អ៊ីសាខស្ថានៈ គេអាចដកចំណែកដីច្រើនខ្លះ យកមកឲ្យអ្នកដែលអត់មាន ។

ស៊ីនឆែនៈ ប៉ុន្តែ គេចែកតាមម៉ាត់ដែរណា យកមកឲ្យបងប្អូនកូនចៅច្រើនដែរណា ក្នុងអ្នកណាដូចថាខ្ញុំកូន២នាក់អញ្ចឹងគេឲ្យតាមកូន២នាក់ ទៅអ្នកណាកូន៥គេឲ្យតាមកូន៥ អ្នកណាកូន១០គេឲ្យតាមកូន១០ ។

អ៊ីសាខស្ថានៈ នៅឆ្នាំណា?

អ្នកជិតខាងៈ ក្រោយ៧៤-៧៥ ។

អ៊ីសាខស្ថានៈ ៧៤-៧៥?

អ្នកជិតខាងៈ ដល់៧៦លែងតែម្តង ធ្វើរួមគ្នា ហូបបាយរួម ។

អ៊ីសាខស្ថានៈ ពេលក្រុមប្រវាស់នឹង១ពាក្យគេហៅថាក្រុមប្រវាស់ដៃ គេមានហៅថាក្រុមសាមគ្គីទេ?

អ្នកជិតខាងៈ គេអត់ហៅក្រុមសាមគ្គីទេ តែគេហៅក្រុមប្រវាស់ដៃ ។

អ៊ីសាខស្ថានៈ ដូចម្ហូប ដូចត្រី បន្លែ សាច់អញ្ចឹងប្រធានក្រុម ឬអ្នកណាជាអ្នកដោះស្រាយ?

អ្នកជិតខាងៈ កាលនឹងយើងនៅចាយលុយទំនើបមួយចំនួនដែរ គេមានសហករណ៍មួយបង្កើតជាសហករណ៍មួយទុកធ្វើសាច់ជ្រូកលក់ ជ្រូកគេដើរទិញតាមផ្ទះគ្រួសាររបស់ប្រជាពលរដ្ឋនឹង យកទៅធ្វើមួយកន្លែងទិញលក់ទៅ ។

អ៊ីសាខស្មាន៖ យកទិញពីសហករណ៍លក់ទៅ ។ ចុះលុយដែលយើងរកបានប៉ុន្មាន បើយើងនៅធ្វើតែស្រែ មានលុយពីណាទៅទិញ?

អ្នកជិតខាង៖ ចុះយើងចិញ្ចឹមមាន់ ចិញ្ចឹមទាយកទៅលក់ឲ្យសហករណ៍គេនឹង ។

ស៊ីនផែន៖ មាន់លក់ឲ្យសហករណ៍ ។

អ៊ីសាខស្មាន៖ អឺ!ចិញ្ចឹមមាន់ទាលក់ឲ្យសហករណ៍ បានលុយមកទិញពីសហករណ៍វិញ?

ស៊ីនផែន៖ ទិញម្ហូប ទិញអីហូប អានឹងគេហៅពាណិជ្ជ១ កន្លែងពាណិជ្ជកម្មគេនឹងណា ។

អ្នកជិតខាង៖ នេះគេលក់នៅកន្លែងសាលារៀនរដ្ឋ ដែលគេទើបនឹងសាងសង់នឹងណា ។

អ៊ីសាខស្មាន៖ ចុះពេលនឹងដូចយើងចិញ្ចឹមមាន់ ចិញ្ចឹមទា បើយើងអត់ចង់លក់ បើយើងចង់ហូបខ្លួនឯងយើងមានសិទ្ធិហូបទេ?

ស៊ីនផែន៖ មាន! កាលនោះមាន ដល់មកនៅឆ្នាំ៧៦-៧៧លែងមានតែម្តង អត់មានសិទ្ធិហូប ទេ កុំថាតែយើងហូបមួយក៏មិនបានផង ។

អ៊ីសាខស្មាន៖ លោកអ៊ំដល់ពេលឆ្នាំ៧៦ លោកអ៊ំនិយាយថា បង្កើតសហករណ៍បាយរួមនឹងនៅខែណាដែរ?

ស៊ីនផែន៖ មិនដឹងខែប៉ុន្មានទេ ។

អ៊ីសាខស្មាន៖ ដើមឆ្នាំ ឬចុងឆ្នាំ ឬពាក់កណ្តាលឆ្នាំ?

ស៊ីនផែន៖ ខ្ញុំក៏មិនដឹងអីទេ ។

អ៊ីសាខស្មាន៖ លោកអ៊ំដឹងថាពេល៧៦អញ្ចឹងអី?

ស៊ីនផែន៖ ចាស!

អ៊ីសាខស្មាន៖ ពេលនឹងគេធ្វើយ៉ាងម៉េច គេមានប្រជុំប្រាប់មុនដែរទេ?

ស៊ីនផែន៖ គេប្រាប់ដែរ ។

អ៊ីសាខស្មាន៖ គេប្រជុំថាយ៉ាងម៉េច?

ស៊ីនផែន៖ គេប្រជុំថាហូបបាយរួមតែម្តង ប្រជុំហូបបាយរួម ពីព្រោះគេអត់មានធ្វើស្រែយកទៅដាក់នៅឯណាទេ ដាក់នៅក្នុងរោងប្រចាំការណ៍នៅនឹង បុកហូបនៅនឹងអីនឹងតែម្តងមានរោងឲ្យហូបអញ្ចឹងណា ដាំបាយនៅនឹង មានឆ្នាំងនៅនឹង យើងទៅតែធ្វើការមកពីធ្វើការទៅហូបនៅកន្លែងតែម្តងទៅណា ។ ដល់ម៉ោងគេវាយជួងទៅ ហូបអ្នកបានឆ្អែតទៅណា ។

អ៊ីសាខស្មាន៖ គេប្រជុំប្រាប់អញ្ចឹងទៅ?

ស៊ីនផែនៈ ចា៎ស! គេប្រជុំប្រាប់ដែរ ។

អ៊ីសាខស្ថានៈ ហើយប្រជាជនមានចិត្តយ៉ាងម៉េចដែរ គាំទ្រដែរឬយ៉ាងម៉េច?

ស៊ីនផែនៈ វាគាំទ្រ អើ! ពិបាកណាស់ យើងនៅក្រោមក្ដាប់គេវាធ្វើអីធ្វើនឹងទៅ គេឲ្យបាយហូបមិនឆ្អែត ។

អ៊ីសាខស្ថានៈ តើចិត្តប្រជាជនចង់ធ្វើសហករណ៍បាយរួមដែរឬអត់ទេ តាមមើល?

ស៊ីនផែនៈ មិនចង់ទេ ប៉ុន្តែអានេះទៅអញ្ចឹងហើយ ចេះតែតាមគេអែបយកតែរស់នឹងទៅ បើតាមថាចិត្តនោះ ។

អ៊ីសាខស្ថានៈ ចុះពេលនោះរំសាយប្រវាស់ដៃ?

ស៊ីនផែនៈ ចា៎ស!

អ៊ីសាខស្ថានៈ ចុះដូចថាចាន ឆ្នាំង ស្រូវអង្ករនៅសល់ផ្ទះ?

ស៊ីនផែនៈ ចាន ឆ្នាំង គេប្រមូលទាំងអស់គ្មាននៅសល់អីទេ ពាងទឹកក៏មិននៅផង ។

អ្នកជិតខាងៈ ចាន ឆ្នាំងតែពាងទឹកក៏គេមិនទុកដែរ គេប្រមូលដាក់នៅក្នុងរោងបាយទាំងអស់ ហើយជង្រុកស្រូវគេធ្វើធំៗ ហើយស្រួចជំនាន់ពាឆ្នាំ៨ខែនឹង ស្រូវៗកើតណាស់ កើតៗទំនប់ ព្រែក ត្រី ជាធម្មតាទេជាង១០ឆ្នាំ រកត្រីបានណាស់ ក្មេងៗមើលក្របីដុះនៅក្បែរវាលនឹងហើយណា ស្រូវកើតណាស់ ។

អ៊ីសាខស្ថានៈ លោកអ៊ំពេលដែលគេប្រមូលបាយរួមអញ្ចឹង ក្រុមប្រវាស់ដៃ ៧-៨-១០គ្រួសារនឹងគេ?

ស៊ីនផែនៈ រលាយអស់ ។

អ៊ីសាខស្ថានៈ គេរំសាយ គេហៅថាក្រុមសហករណ៍វិញ?

ស៊ីនផែនៈ ចា៎ស! ក្រុមសហករណ៍ ។

អ៊ីសាខស្ថានៈ ដូចថាមួយសហករណ៍នឹងមានគ្នាប៉ុន្មានទៅ?

ស៊ីនផែនៈ ច្រើនដែរ ប្រហែល១០០គ្រួសារ ។

អ៊ីសាខស្ថានៈ មួយភូមិនឹងមានប៉ុន្មានសហករណ៍?

ស៊ីនផែនៈ មួយភូមិគេធ្វើ២រោងបាយ រោងនោះមួយ រោងនៅនេះមួយ មួយភូមិស្វាយយានឹងណា ។

អ្នកជិតខាងៈ ដល់ឆ្នាំ៧៨ប្រមូលតែមួយរោងបាយទេ ។

អ៊ីសាខស្ថាន: អញ្ចឹងកាល៧៦រោងបាយមាន២ បានន័យថាមាន២សហករណ៍ ដល់៧៨នេះមួយសហករណ៍ ។

អ្នកជិតខាង: ប្រមូលមកតែរោងបាយតែមួយ ។

អ៊ីសាខស្ថាន: ចុះអ៊ី! លោកអ៊ំគិតមើល ខ្ញុំចង់សួរពីដើមមកបន្តិច ពេលដែលធ្វើគេហៅថាប្រវាស់ដៃនឹង ហើយនឹងការងារឯកជនពីដើមមកនឹង មួយណាប្រសើរជាងមួយណា ប្រវាស់ដៃមិនមែនសហករណ៍បាយរួមទេណា?

ស៊ីនផែន: ខ្ញុំថាធ្វើតាមដំបូលផ្ទះអញ្ចឹង ខ្ញុំថាស្រួលជាងខាងក្រុមប្រវាស់ដៃណា ព្រោះធ្វើនេះថាអ្នកខ្មែរតិចវាឆាប់ហើយ ហើយអ្នកខ្មែរច្រើន យើងវាហាត់យូរក្រហើយ តែនៅតែធ្វើតាមប្រពៃណីរបស់គេដែរណា គេឲ្យធ្វើអញ្ចឹងយើងគោរពតាមតែគេទៅ ហើយដល់ពេលធ្វើទៅមិនជាល្អក់កក់ប៉ុន្មានដែរណា ចេះតែអត់ឱនឲ្យគ្នាទៅណា ធ្វើៗទៅគេគាញទៅរកបាយរួមទៅណា ។

អ៊ីសាខស្ថាន: លោកអ៊ំខ្ញុំចង់សួរមួយទៀត ឧបមាថាដូចអ្នកខ្លះអត់មានដីស្រែ ហើយគេចែកស្រែឲ្យគាត់ធ្វើ ហើយគាត់មិនសូវពូកែធ្វើស្រែ ដោយសារតែពីមុនមកគាត់អ្នករកស៊ី ផ្សេងគាត់អ្នកលក់ដូរ គាត់អ្នកធ្វើជាង ធ្វើការងារផ្សេង តែគាត់អត់ដែរធ្វើស្រែ សោះនោះមានអ្នកអញ្ចឹងទេ?

ស៊ីនផែន: មានខ្លះដែរ ។

អ៊ីសាខស្ថាន: ហើយបើមានអញ្ចឹងអ្នកនោះមិនចេះធ្វើស្រែសោះផង ហើយទៅដល់ស្រែខ្លួនឯងគេពេញចិត្តនឹងធ្វើឲ្យគាត់នឹងដែរ?

ស៊ីនផែន: ពេលចិត្តៗអ៊ី ចេះតែទៅនឹងគេនឹងឯងទៅណា គេរុញឲ្យទៅណាចេះតែទៅតាមគេទៅណា យើងចេះតែទៅតាមគេទៅណា ។ មិនមែននេះអ្នកនារតី តែបើនិយាយពីមុនអ្នកខាងមុខជ្រៅទៅគេរកស៊ីទៅណា ។

អ៊ីសាខស្ថាន: ខ្ញុំចង់សួរមួយទៀតប្រជាជនជម្លៀសមានមកភូមិនេះទេ?

ស៊ីនផែន: មាន មកពីត្បូងអីនឹង ។

អ្នកជិតខាង: មកពីភ្នំពេញ ។

អ៊ីសាខស្ថាន: មកពីភ្នំពេញ?

ស៊ីនផែន: ចា៎ស!

អ៊ីសាខស្ថាន: អញ្ចឹងអ្នកដែលមកពីភ្នំពេញមានចូលក្នុងក្រុមប្រវាស់ដៃឬទេ?

ស៊ីនផែនៈ	ចូលពេលស៊ីបាយរួមមួយជំនាន់ស៊ីបាយរួមនឹងគេធ្វើស្រែ ។

អ៊ីសាខស្នានៈ	អត់មានចូលក្នុងក្រុមប្រវាស់ដៃទេ?

ស៊ីនផែនៈ	អត់មានចូលទេ មកអត់ទាន់ផង ។

អ៊ីសាខស្នានៈ	មកអត់ទាន់ទេ គេរំសាយប្រវាស់ដៃហើយបានប្រជាជនភ្នំពេញមកដល់?

ស៊ីនផែនៈ	ចាស!មកដល់ចូលបាយរួមតែម្ដង ចូលបាយរួមនឹងគ្នាខំធ្វើ ចេះសួងមិនចេះសួង អីចេះតែទៅៗនឹងគេនឹងឯង ។

អកជិតខាងៈ	អ្នកខ្លះទៅនៅរស់ ខ្លះទៅងាប់ដោយអត់អាហារ ខ្លះទៅងាប់ដោយពួកប៉ុលពតយកទៅសម្លាប់ ឲ្យតែពួកសៗមិនថាចិនឬយួនងាប់ខ្ទេច ។

អ៊ីសាខស្នានៈ	ចុះអីការហូបចុកដូចដែលនៅក្រុមសហករណ៍រោងបាយមួយ មួយភូមិនឹង ឬរោងបាយពីរមួយភូមិនឹង តើមានបញ្ហាអីកើតឡើងទៅ ចំពោះការហូបចុក?

ស៊ីនផែនៈ	យ៉ាប់ ។

អ៊ីសាខស្នានៈ	យ៉ាប់យ៉ាងម៉េចទៅអ៊ំ?

ស៊ីនផែនៈ	យ៉ាប់ ហូបមិនឆ្អែត ហើយម្យ៉ាងទៅម្ហូបនឹងវាខ្វះខាតអញ្ចឹងដែរណា មានអីស្លបន្លែៗមានសាច់គ្មានអីហូបទេ ទ្រាំៗទម្រាំបានរស់រាន់មានជីវិតដែលបានអង្គការយើងរំដោះមកបានរួចទុក្ខទោសនឹង ខ្ញុំថាវាហួសចិត្តហើយ ។

អ៊ីសាខស្នានៈ	លោកអ៊ំម៉េចបានជាខ្វះខាត ព្រោះថាចំនួនប្រជាជននៅដដែល ហើយដីស្រែនៅដដែល?

ស៊ីនផែនៈ	នៅដដែល តែគេមិនឲ្យយើងហូបណា វាមិនឲ្យយើងហូបមិនបានដិតមិនបានដល់ដូចកូនក្មេងកូនក្មាំងអីក៏អញ្ចឹងដែរហូបមិនបានដិតសល់ទេ ។

អ៊ីសាខស្នានៈ	មូលហេតុអី?

ស៊ីនផែនៈ	មិនដឹងយ៉ាងម៉េច វាសំចៃស្រូវសំចៃអង្ករមិនដឹងទុកយកទៅណាអស់មិនដឹងដែរខ្ញុំ ។

អ៊ីសាខស្នានៈ	ចុះប្ដីអ៊ំជាមេឃុំដែរ?

ស៊ីនផែនៈ	មេឃុំគេចាប់យកទៅមុន គេយកទៅមុនបាត់ហើយ គេឡើងមេឃុំក្រោយទៀតៗនឹងលេខមួយតែម្ដង ។

អ៊ីសាខស្នានៈ	ចុះថាប្ដីអ៊ំគេចាប់នៅឆ្នាំ៧៧?

ស៊ីនផែនៈ	ឆ្នាំ៧៧ តែកាលនោះមិនទាន់តឹងពេកទេ មិនទាន់តឹងពេញទេ តែដល់ក្រោយមកបានតឹងមែនទែន តែក្មេងនឹងហូបបាយ តឹងខ្លាំងឡើងៗ ពិបាកៗនោះពិបាក ។

អ៊ីសាខស្ងួនៈ ការហូបចុកកន្លែងយ៉ាងម៉េច បានជាអ៊ំគិតថាការហូបចុកនឹងពិបាក?

ស៊ីនផែនៈ ពិបាកការហូបចុក ហូបមិនឆ្អែតៗ ហើយធ្វើការគ្មានដឹងពេលដឹងវេលា គ្មានសម្រាកសម្រាន្តសុខស្រួលទេ យើងចេះតែទៅតគ្រុកទៅៗ ធ្វើឲ្យទៅណាទៅនឹងឡើងទៅតាំងពីម៉ោងមួយម៉ោងពីរ ។

អ៊ីសាខស្ងួនៈ ម៉ោងមួយម៉ោងពីរព្រឹកជិតភ្លឺនឹង?

ស៊ីនផែនៈ ចាស!

អ៊ីសាខស្ងួនៈ ហើយមើលម៉េចឃើញទៅ ម៉ោងមួយម៉ោងពីរ?

ស៊ីនផែនៈ ចេះតែទៅៗ ត្រៀមទៅ ហើយយើងមិនធ្វើមិនអីទៅគេ... ។

អ៊ីសាខស្ងួនៈ ហើយម៉ោងប៉ុន្មានបានឈប់?

ស៊ីនផែនៈ ម៉ោង១១ - ១២អីនឹង ។

អ៊ីសាខស្ងួនៈ ចុះម៉ោង៦ - ៧អត់ឈប់ហូបបាយ គេឲ្យបាយឲ្យបបរ?

ស៊ីនផែនៈ បាយអី គេឲ្យបាយមកពីផ្ទះមកៗ ហូបកន្លែងរោងបាយ ដើរទម្រាំមកដល់ ។

អ៊ីសាខស្ងួនៈ អញ្ចឹងចាប់ពីម៉ោង១ព្រឹកទៅដល់ម៉ោង១១ ហើយចុះម៉ោងប៉ុន្មានទៀតទៅ?

ស៊ីនផែនៈ ចុះដក ប្រហែលម៉ោង២យ៉ាង! ម៉ោង២ចុះដកវិញទៀត ដកវាល់គ្របរ ។

អ៊ីសាខស្ងួនៈ ហើយឈប់ម៉ោងប៉ុន្មាន?

ស៊ីនផែនៈ ឈប់ម៉ោង៥ សម្រាក ។ អើយយ៉ាប់ណាស់ ខ្ញុំនឹកឃើញកាលនឹងទៅខ្ញុំរស់នៅ... វាស្រួលដែរ ។

អ៊ីសាខស្ងួនៈ អញ្ចឹងលោកអ៊ំដែលនិយាយអំពីរឿងសម័យខ្មែរក្រហម ពីរឿងការហូបចុក ការស្លាប់បងប្អូនអញ្ចឹងប្រាប់ក្មេងៗសម័យឥឡូវដែរទេ?

ស៊ីនផែនៈ ខ្ញុំនិយាយដែរ តែក្មេងៗវាម៉េចមិនចាំ... ។

អ៊ីសាខស្ងួនៈ អ៊ំខស្សាហ៍និយាយប្រាប់ក្មេងៗដែរ?

ស៊ីនផែនៈ ចាស!និយាយឡើងធុញ ។

អ៊ីសាខស្ងួនៈ ហើយក្មេងៗជឿអ៊ំទេ?

ស៊ីនផែនៈ វាម៉េចមិនជឿ វាថាកាលនឹងយើងធ្វើបាបវាដង ។ ពួកនឹងធ្វើបាប ។

អ៊ីសាខស្ងួនៈ ធ្វើបាបវាយ៉ាងម៉េច?

ស៊ីនផែនៈ ធ្វើបាបដូចថា កាលនឹងវាមិនចង់ឲ្យមាន វាស្អប់ វាថាយើងនឹងមិនមែននិយាយថាពីរឿងមួយបក្សខ្មែរក្រហម មួយបក្សខាងពួកប៉ុលពត វាមិនថាអញ្ចឹង វាថារួមទាំង

អស់ វាយយកទាំងអស់ ដូចថាប៉ុលពត ខ្មែរក្រហមអីដូចគ្នាអញ្ចឹងណា មិនមែនថា ដោយឡែកៗអញ្ចឹងណា ។

អ៊ីសាខស្ថាន: លោកអ៊ីគិតថា គួរតែមានការចងក្រងជាឯកសារប្រវត្តិសាស្ត្រ ទុកឲ្យក្មេងៗសម័យក្រោយបានដឹងពីរឿងខ្មែរក្រហមនឹងដែរឬអត់?

ស៊ីនផែន: ខ្ញុំចងក្រង ខ្ញុំមិនចេះអក្សរដែរ ។

អ៊ីសាខស្ថាន: ឧបមាថា លោកអ៊ីអ្នកនិយាយប្រាប់ ហើយខ្ញុំអ្នកយកទៅសរសេរទុកឲ្យក្មេងបាន អានបានដឹងអញ្ចឹង តើលោកអ៊ីគិតថាធ្វើអញ្ចឹងមានផលប្រយោជន៍ឬទេ?

ស៊ីនផែន: អើ!ថាគ្មានទេ ទៅជាមាន ដូចថាមានទៅជាគ្មាន ខ្ញុំចេះតែថាៗ បើតាមចិត្តខ្ញុំៗថាក្រែងលោ អង្គការសួរចង់ដឹងអីយ៉ាងម៉េចយ៉ាងណាៗ ក៏គ្មានផលប្រយោជន៍អីដែរ គ្រាន់តែថាយកទៅផ្សាយអញ្ចឹងទៅណា ជាព័ត៌មានអីនេះទៅ ខ្ញុំក៏...។

អ៊ីសាខស្ថាន: អ៊ីពេលដែលពួកខ្ញុំមកជួបអ៊ី ហើយសួរពីរឿងរ៉ាវដ៏យូរអង្វែងមកហើយ ដែលអ៊ីបានឆ្លងកាត់អញ្ចឹងនឹងណា អ៊ីមានអារម្មណ៍យ៉ាងម៉េចដែរ?

ស៊ីនផែន: ខ្ញុំគ្មានអារម្មណ៍អីទេ ។

អ៊ីសាខស្ថាន: អ៊ីគិតថាបាននិយាយជាមួយខ្ញុំទៅ បានធូរស្រាយក្នុងចិត្តណាស់ ឬក៏គិតថាពួកខ្ញុំមកបានសួរអញ្ចឹងកាន់តែធ្វើឲ្យអ៊ី ពិបាកឡើងវិញនឹងឃើញពីរឿងនឹងឡើងវិញ?

ស៊ីនផែន: ខ្ញុំគ្មានអារម្មណ៍អីទេ វាហើយអស់ទៅហើយពីរឿងមុននឹងនោះ ចប់អស់ទៅហើយ ខ្ញុំដឹងអារម្មណ៍អីខ្ញុំទេ ។ បើអង្គការតម្រូវត្រូវថាស្អប់ពួកខ្មែរក្រហមយកទៅសម្លាប់ចោល ក៏យកទៅសម្លាប់ទៅ មិនដឹងយ៉ាងម៉េចទេ វាត្រូវអញ្ចឹងទៅហើយ ។

អ៊ីសាខស្ថាន: ចុះអ៊ីស្អប់ទេ?

ស៊ីនផែន: ខ្ញុំកាលម៉ាក់នេះនឹង ខ្ញុំមិនស្អប់ទេ ប៉ុន្តែក្រោយមកគេធ្វើពួកក្រោយនេះ ខ្ញុំស្អប់ខឹង ។

អ៊ីសាខស្ថាន: ពួកក្រោយនេះពួកណាវិញ?

ស៊ីនផែន: អានេះមិនមែននេះ ដូចថាខ្មែរក្រហមមួយបក្សខ្មែរក្រហមនេះណា ហើយដល់មួយបក្សនេះទៀត អានេះមិនចំតួជាខ្មែរក្រហមទេ អានឹងចំតួក្បត់ជាតិអញ្ចឹងណា ។

អ៊ីសាខស្ថាន: អឺ!ពួកក្បត់ជាតិ?

ស៊ីនផែន: ចាស!ក្បត់ជាតិ ព្រោះបើមិនក្បត់អីសម្លាប់តាំងពីកូនក្មេងកូនក្មាំង ប្រជាជនអញ្ចឹងយកគ្នាទៅវាយចោលទាំងអន្ទង់ៗ យើងថាម៉េច អានឹងមិនក្បត់ជាតិ ។

អ៊ីសាខស្ថាន: បាទ!ពីដើមអត់មានវាយអញ្ចឹងទេ?

ស៊ីនផែនៈ ពីដើមវាយអី សម្រុះសម្រួលគ្នាស្រួលសឹងស្លាប់ ។

អ៊ីសាខស្នានៈ ខ្មែរក្រហមពីមុនមក?

ស៊ីនផែនៈ ចាស!ពីមុនមានសម្លាប់ឯណា មានសម្លាប់អី គេមានធ្វើខុសអី ប្រជាជនគេមិនដឹងធ្វើខុសអី ។ អានេះទាល់តែមានក្បត់ទើបបានគេសម្លាប់ បើយើងអត់ក្បត់ អត់ដឹងអត់ព្វអីផង ទៅសម្លាប់ម៉េច ។ សម្លាប់តែមួយពេលដែលក្បត់ក្រោយមកៗនឹងសម្លាប់គ្មានដឹង ប្រជាជនទៅ ។

អ៊ីសាខស្នានៈ ពួកណាដែលមកកាន់កាប់នឹង ដែលពួកអ៊ំគិតថាក្បត់នឹង ពួកណាដែរ?

ស៊ីនផែនៈ ខ្ញុំអត់ដឹងថាពួកណាទេ ប៉ុន្តែខ្ញុំដឹងថាមួយជំនាន់ប៉ុលពត អៀងសារី តែម្តង ។

អ៊ីសាខស្នានៈ ចុះដូចសព្វថ្ងៃ អៀងសារីគាត់នៅរស់ ហើយកាលសម័យនឹងគាត់ជាអ្នកកាន់កាប់កាន់អំណាចខ្ពស់ដែរ នួនជាអីនឹង ខៀវសំផននឹង គាត់សុទ្ធតែជា?

ស៊ីនផែនៈ ដែលខៀវសំផននឹង កាលពីដើមពូកែណាស់ខាងខ្មែរក្រហម ប៉ុន្តែដល់ក្រោយមកទាំងអស់តែម្តង ទាញក្បាលគ្នាឯងយកទៅសម្លាប់ចោលតែម្តង ខ្ញុំនឹកឃើញ ។

អ៊ីសាខស្នានៈ អញ្ចឹងលោកអ៊ំគិតថា ចាប់ពួកអ្នកដឹកនាំនៅរស់នឹងយកមកកាត់ទោសតាមផ្លូវច្បាប់ដែរឬទេ?

ស៊ីនផែនៈ បើតាមចិត្តខ្ញុំខឹង គ្រួសារខ្ញុំស្លាប់អស់មួយគំនរ ខ្ញុំខឹងដែរ ខ្ញុំចង់តែ បើសិននេះទេគួរតែឲ្យគេចាប់យកមកប្រល័យជីវិតឲ្យអស់ៗស្អប់ណាស់ ព្រោះប្រជាជន ខ្ញុំមើលម៉ក់ៗមកពីឆ្ងាញអញ្ចឹង គ្នាកំពុងតែហូបបាយអញ្ចឹងហៅគ្នាយកទៅវាយចោលអស់ខ្ញុំនឹកឃើញអាណិតប៉ុននឹង ខ្លោចផ្សា ហើយគ្រួសារខ្ញុំគ្មានដឹងរឿងអីសោះនឹងចាប់យកទៅចងដឹកគ្នាទាំងថ្ងៃ យើងមិនដឹងដឹកនាំខុសពីរឿងអី ប្រជាជនគេធ្វើសស្រាក់សស្រាំ យើងធ្វើសប្បាយគគឹកគគេងណាស់មិនមានទាស់គ្នាផង ហើយដល់អញ្ចឹងចាប់គ្នាអូសយកទៅ ឃើញខ្ញុំឃើញនឹងភ្នែកដែលអ្នកគេធ្វើការៗ មើលអ្នកដឹកនាំទាំងអស់ចាប់សុទ្ធតែមេអ្នកដឹកនាំ អ្នកខ្ពីមៗយកអស់រលីង ហើយបានយកប្រជាជនទៅតាមក្រោយ យកប្រធានភូមិ ប្រធានអីចាប់ចងគ្នាដឹក ហើយឲ្យគ្នារត់តាមកង់ តាមឡានអីវាសមទេ ធ្វើអញ្ចឹងវាហួសពេក ។

អ៊ីសាខស្នានៈ ចាប់នឹងរត់តាមកង់តាមឡានយ៉ាងម៉េចអ៊ំ?

ស៊ីនផែនៈ រត់ទៅ ឲ្យចងយើងទៅ ហើយវារត់ទៅមុន ហើយឡានបើកតាមក្រោយ ឬម៉ូតូកង់ដេញតាមក្រោយទៅណា ឲ្យរត់មុនកង់ទៅណា ។

អ៊ីសាខស្ថានៈ ចាប់ពីណាខ្លះ ធ្វើអញ្ចឹង?

ស៊ីនឆែនៈ តាមភូមិ ឃុំអីអញ្ចឹងទៅណា តាមគណៈភូមិ គណៈឃុំអីអញ្ចឹងទៅណា ចាប់ទៅសុទ្ធតែធ្វើអញ្ចឹង ។

អ៊ីសាខស្ថានៈ តែប្ដីលោកអ៊ំ គេអត់ធ្វើអញ្ចឹងឯណា?

ស៊ីនឆែនៈ គ្រួសារខ្ញុំគេចាប់យកទៅមិនដឹងធ្វើម៉េច ខ្ញុំអត់បានឃើញនឹងភ្នែកផង ។

អ៊ីសាខស្ថានៈ ចុះអ៊ំបានឃើញនឹងភ្នែកផ្ទាល់ទេ ដូចថាចាប់ចងហើយ ឲ្យរត់មកតាម?

ស៊ីនឆែនៈ ឃើញៗផ្ទាល់តែម្ដង ។

អ៊ីសាខស្ថានៈ ឃើញនៅកន្លែងណា?

ស៊ីនឆែនៈ ខ្ញុំឃើញនៅឯស្វាយជ្រៃនោះ ខ្ញុំទៅជីកដីនៅក្បែរវត្តស្វាយជ្រៃ ឃើញគេចង បើកភ្នែកឡើងគេចងមកអញ្ចឹង ចងដាក់ដៃទៅក្រោយដាក់ខ្នោះ គេឲ្យរត់ទៅមុខដងអញ្ចឹងទៅហើយកង់បេះតែជិះតាមក្រោយទៅណា រត់ទៅបេះតែទៅហើយ ខ្ញុំអានោចអាធមណាស់ នឹកឃើញ ។

អ៊ីសាខស្ថានៈ ប៉ុន្មាននាក់ដែលអ៊ំឃើញ?

ស៊ីនឆែនៈ ខ្ញុំឃើញច្រើនណាស់ សឹងតែគ្រប់ភូមិៗណាក៏គេចាប់ទៅដែរ ។

អ៊ីសាខស្ថានៈ ប្រធានភូមិ ប្រធានឃុំ?

ស៊ីនឆែនៈ ចាស!

អ៊ីសាខស្ថានៈ ហើយពួកណាមកចាប់?

ស៊ីនឆែនៈ ពួកអាពតតែម្ដង ។

អ៊ីសាខស្ថានៈ ពួកអាពតដែលថាក្បត់នឹង?

ស៊ីនឆែនៈ ចាស!ពួកក្បត់នឹងណា មិនដឹងពីណាទេ ដែលអ្នកដែលគេធ្វើតាមនៅខាងសង្កត់ក្រោយពីគ្រួសារខ្ញុំមកនឹងណា សុទ្ធតែចិនតែម្ដងទៅណា ។

អ៊ីសាខស្ថានៈ លោកអ៊ំគិតថា គួរតែមានតុលាការសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់នឹងដែរ?

ស៊ីនឆែនៈ ខ្ញុំមិនសូវដឹងទេរឿងនឹងណា ។

អ៊ីសាខស្ថានៈ ចុះសព្វថ្ងៃនេះ ខ្ញុំជម្រាប់អ៊ំថារដ្ឋាភិបាលកំពុងតែគិតគូរពីរឿងបញ្ហាកាត់ទោសនឹង ណាកាតទោសដូចអៀងសារី ឬខៀវសំផន តាម៉ុក នួនជា ដែលជាមេដឹកនាំនៅក្នុងសម័យនឹង ហើយដែលគេដឹងថាពួកគាត់សុទ្ធតែពាក់ព័ន្ធទាក់ទងបឹងបញ្ហាសម្លាប់

មនុស្ស ជាអ្នកដែលគេបញ្ជាឲ្យសម្លាប់នឹងណា ហើយនៅពេលដែលគេកាត់ទោស នឹងច្បាប់ស្រុកខ្មែរយើងសព្វថ្ងៃនេះ អត់មានបទប្រហារជីវិតទេ គ្រាន់តែកាត់ទោស ឲ្យជាប់គុកតែប៉ុននឹងណា ។ ហើយលោកអ៊ំគិតថាប៉ុននឹង លោកអ៊ំបានស្ងប់ចិត្តខ្លះទេ ប្រសិនជាត្រឹមតែការកាត់ទោសកម្រិតនឹង?

ស៊ីនផែនៈ ឲ្យតែវាលែងច្បាំងគ្នានឹងបានហើយ ។ តែឥឡូវស្រេចតែតុលាការទេ បើខ្ញុំមិនដឹងអីទេ បើតុលាការកាត់ទោសក៏កាត់ទៅ បើតុលាការទុកក៏ទុកទៅ តែធ្វើម៉េចកុំឲ្យច្បាំងគ្នាទៀតបានហើយ ។

អ៊ីសាខស្មានៈ សំខាន់អ៊ំមិនចង់ឲ្យមានច្បាំងគ្នាទៀតទេ?

ស៊ីនផែនៈ ចាស!ខ្ញុំមិនចង់ទេ ខ្ញុំខ្លាចណាស់ពិបាករស់ណាស់ ខ្ញុំធ្លាប់បានជួបអស់ហើយ ខ្លាចណាស់ រត់កាត់គ្រាប់ក៏មានរត់អីក៏មាន ខ្ញុំធ្លាប់អស់ហើយដៃម្ខាងពរកូន ដៃម្ខាងកាន់បង្វិច ទៅចេះតែទៅហើយ គ្រប់តែគន្លាគគន្លោះ ។

ឡុងដានីៈ អ៊ំដែលឃើញកន្លែងសន្តិសុខ កន្លែងអីគេ ដូចថាគេចាប់ពីនេះទៅយកទៅដាក់កន្លែងណាៗ?

ស៊ីនផែនៈ គេយកទៅកន្លែងសន្តិសុខ នៅធ្លោក ។

ឡុងដានីៈ ធ្លោកនឹងក្នុងឃុំអីដែរ?

ស៊ីនផែនៈ ឃុំធ្លោក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀងដែរ ។

ឡុងដានីៈ អញ្ចឹងគេចាប់ពីតាមភូមិតាមអីនឹង ដាក់នៅធ្លោកទាំងអស់?

ស៊ីនផែនៈ ចាស!គេដាក់នៅធ្លោក តែគេបញ្ជូនពីធ្លោក មិនដឹងយកទៅណាទៀតទេ ។

ឡុងដានីៈ ចុះកន្លែងមន្ទីរសន្តិសុខនៅធ្លោក មន្ទីរសន្តិសុខរបស់ស្អីគេ ដូចជារបស់ឃុំ របស់ស្រុកឬរបស់តំបន់?

ស៊ីនផែនៈ ចាស!របស់ស្រុក ។

ឡុងដានីៈ របស់ស្រុកស្វាយជ្រំតែម្តង?

ស៊ីនផែនៈ ចាស!

ឡុងដានីៈ អ៊ំដែលឃើញៗ ដែលទៅធ្លោកនឹងឃើញៗអ្នកទោសនៅនឹងដែលគេចាប់ទៅ?

ស៊ីនផែនៈ ថីមិនឃើញៗដែរ ខ្ញុំទៅនឹងដែរ ខ្ញុំខស្សាហ៍ទៅដែរ ។

ឡុងដានីៈ អ្នកទោសដែលគេចាប់ទៅធ្លោកនឹងច្រើនជាប្រភេទអ្នកទោសអីទៅ?

ស៊ីនផែនៈ អឺ!អ្នកទោសមិនដឹងជាអ្នកទោសអ្វីៗទេណា ខ្ញុំក៏ទៅឃើញអ្នកខ្លះទៅដូចថាវាប្រឆាំង អីញ្ចឹងទៅណា វាមិនមែននេះទេណា ដូចថាគេធ្វើអញ្ចឹងទំនាស់គ្នាទៅក៏ចាប់យកទៅ សុទ្ធតែថាធ្វើចេះមិនត្រូវ ធ្វើចុះមិនត្រូវអី ក៏ចាប់ទៅ អានឹងវាអញ្ចឹង វាមិនមែន ថា ពិបាកណាស់ ។

ឡុងដានីៈ ចុះកន្លែងគេយកទៅសម្លាប់?

ស៊ីនផែនៈ កន្លែងគេយកទៅសម្លាប់ គ្រប់នេះតែម្តងគ្មានដឹងកន្លែងណាជាកន្លែងណៃទេ អាពួកនឹងយកទៅសម្លាប់ឲ្យតែមានគុំបូកមានព្រៃនឹង ពួយទាំងអស់មិនដឹងទីណាទេ ។...នេះ លិចនឹងវត្តគោកចកនឹង ឬស្សី ចឹងនឹងពីវត្តគោកចកទៅត្បូង ។

ឡុងដានីៈ ចុះអ៊ីខាងគណៈស្រុកមានជ័យថ្មី ឬគណៈស្រុកស្វាយជ្រំ កាលជំនាន់ប៉ុលពត?

ស៊ីនផែនៈ មានជ័យថ្មី ។

ឡុងដានីៈ កាលនឹងគណៈស្រុកមានជ័យថ្មីឈ្មោះអីទៅ?

ស៊ីនផែនៈ តាសាមិត្ត ខៀវសាមិត្ត ។

ឡុងដានីៈ គាត់មកពីខាងណា?

ស៊ីនផែនៈ នៅតាកែវ ខេត្តតាកែវ ស្អាតណាស់ បងសាមិត្តសស្គុះ ហើយនិយាយល្អើនៗ មកនៅទីនោះ...។

ឡុងដានីៈ តាខៀវសាមិត្តនឹង គាត់គណៈស្រុកតាំងពីឆ្នាំ៧៥មកដល់៧៩ ឬគាត់ធ្វើតាំងពីអន្តាល់មក?

ស៊ីនផែនៈ ធ្វើពីមកពីឆ្នាំហើយ មកពីឆ្នាំ៧៥ ធ្វើឆ្នាំ៧៥មកដល់ឆ្នាំ... បាត់ពីស្រែករពូថុច បាត់ប្រហែល៧៦ ៧៧មកពួកឪអានាងខ្ញុំទេណា ។ ៧៦ហើយគាត់បាត់ពីឆ្នាំនឹង បាត់មុនគ្រួសារ ។

ឡុងដានីៈ ដល់ពេលផុតពីតាសាមិត្តនឹងទៅគណៈស្រុកពីណាគេទៀត?

ស៊ីនផែនៈ មិនដឹងពីណា ខ្ញុំមិនដឹង ខ្ញុំលែងស្គាល់ហើយមិនដឹងពីណា ។

ឡុងដានីៈ ចុះក្រៅពីតាសាមិត្តនឹង មានពីណាផ្សេងទៀតដែលដូរក្នុងគណៈស្រុកដែរ?

ស៊ីនផែនៈ ដូរគណៈស្រុកនឹងក្រោយនឹងខ្ញុំលែងដឹងតែម្តង លែងស្គាល់ ខ្ញុំអត់ស្គាល់ និយាយមែនទែនចាំបងធន់ៗ តែធន់នឹងចាំដែរឬអត់ ធន់នៅស្វាយជ្រំនៅអន្លុកប្បាស ។

ឡុងដានីៈ ដូចខាងគណៈស្រុកអី គេខស្សប្រាហ៍ចុះមកប្រជុំនិយាយអីជាមួយប្រជាជនដែរអត់?

ស៊ីនផែនៈ គេចឹងនឹងដែរ គេខស្សប្រាហ៍មកសឹងអី ។

ឡុងដានី: គេខស្សាហ៍មកប្រជុំម្តងៗ គេច្រើននិយាយយ៉ាងម៉េចខ្លះទៅ។

ស៊ីនផែន: អឺ!និយាយ ខ្ញុំក៏ភ្លេចអស់ហើយដែរនឹងណា មិនដឹងនិយាយស្អី ការងារច្រើនណាស់ដែរនឹងណា អារឿងខ្ញុំធ្វើបដិវត្តិនឹងណា គេនិយាយក្បោះក្បាយរបស់គេដែរនឹងណា នឹងគណៈស្រុករបស់បងខៀវសាមិត្ត មានអីទេ។ ប៉ុន្តែដល់ក្រោយមកខ្ញុំដូចដឹងដែរគណៈស្រុកក្រោយដូចមាន...វាចន្លោះមិនដែលឃើញមិនដែលអី តាំងពីនឹងមកដូចថាវារៀងចារមិនមើលគេមិនហ៊ានតែម្តង ខ្លាចគេ។

ឡុងដានី: ចុះអ៊ំគណៈតំបន់វិញ?

ស៊ីនផែន: គណៈតំបន់ពូថុចខ្ញុំ។

ឡុងដានី: តាថុចនឹងគណៈតំបន់២៣នឹង?

ស៊ីនផែន: ចាស!តំបន់២៣។

ឡុងដានី: ទីតំបន់គេនៅឯណាទៅ?

ស៊ីនផែន: នៅស្វាយរៀង។

ឡុងដានី: តាថុចនឹងខស្សាហ៍ចុះមកនឹងដែរឬអត់?

ស៊ីនផែន: អឺ!ចុះស្រុកនៅនឹង ផ្ទះគាត់នៅនឹង ពូវា ពូខ្ញុំទាំងអស់គ្នា។

ឡុងដានី: ខស្សាហ៍មកលេងផ្ទះដែរ?

ស៊ីនផែន: ហើយមកៗរកនេះនឹង ហើយកន្លែងគាត់ធ្វើនៅកន្លែងខាងនេះមួយ ហើយគាត់នៅស្វាយរៀងនឹងប្រពន្ធគាត់នៅនឹង បានកូនមួយ ហើយកូនសព្វថ្ងៃនៅភ្នំពេញ ហើយប្រពន្ធគាត់នៅខាងត្បូងវាំង។

ឡុងដានី: ប្រពន្ធគាត់មានឈ្មោះអីគេ តាថុចនឹង?

ស៊ីនផែន: ឈ្មោះ...ឡៃហៀង។ ឥឡូវគាត់ទៅនៅឯណា នៅគីរីរម្យ ទៅនៅកាប់ដីដាំចម្ការនៅនឹង ចាំដីប្រពន្ធតាសុង។ នៅគីរីរម្យនៅខាងណាត្រែងត្រយឹងខាងណាមិនដឹង ខាងលិច ខាងជើងមិនដឹងទេ។

ឡុងដានី: ចុះខាងភូមិភាគអីអ៊ំស្គាល់ឬអត់?

ស៊ីនផែន: ខាងណា?

ឡុងដានី: គណៈឃុំភាគ?

ស៊ីនផែន: គណៈភូមិភាគ នេះនឹង តាឈូក។

ឡុងដានី: តាឈូក ក្រែងគាត់ជាគណៈតំបន់២៤ទេ?

ស៊ីនផែនៈ	អើ!មែន គណៈតំបន់២៤ ។...ដឹងថាតាឈូកគណៈតំបន់២៤ ។

ឡុងដានីៈ	តាថុចគណៈតំបន់២៣នឹង គាត់ចុះមកខាងស្រុកយើង គាត់មកលេង ឬគាត់មកធ្វើការ?

ស៊ីនផែនៈ	មកធ្វើការផង អើ!ស្រុកកំណើតនៅនឹង គាត់ខស្សាហ៍មក គាត់ធ្វើការនៅនឹងផង ។

ឡុងដានីៈ	គាត់ធ្វើការខាងគណៈស្រុក គណៈឃុំផង?

ស៊ីនផែនៈ	នឹងហើយ ធ្វើទាំងអស់ ។

អ៊ីសាខស្នានៈ	គាត់រៀនបានខ្ពស់ដែរ?

ស៊ីនផែនៈ	ចា៎ស!បានសញ្ញាប័ត្រ ជាប់សញ្ញាប័ត្រ ។

អ៊ីសាខស្នានៈ	សញ្ញាប័ត្រអី?

ស៊ីនផែនៈ	សញ្ញាប័ត្រពីដើម យើងពីដើមជំនាន់៦០ប៉ុន្មាន មើលកាលនឹងវាខ្ពស់ដែរ ។

អ៊ីសាខស្នានៈ	រៀននៅឯណា?

ស៊ីនផែនៈ	មើល!រៀននៅបោះព្រីង រៀននៅភ្នំពេញ ។

អ៊ីសាខស្នានៈ	បានទៅរៀននៅភ្នំពេញដែរ?

ស៊ីនផែនៈ	ចា៎ស!

អ៊ីសាខស្នានៈ	ប៉ុន្មានឆ្នាំ?

ស៊ីនផែនៈ	មនដឹងប៉ុន្មានឆ្នាំទេណា គាត់ទៅរៀនទេះណា ។...អើយឪប្ដូមសញ្ញាប័ត្រនឹង កាលនឹងជាមួយធំឯង ក្រែងធំឯងសញ្ញាប័ត្រដែរ កាលជំនាន់នឹងបានសញ្ញាប័ត្រជាមួយគ្នាដែរ ។ ពូក៏ប៉ុននឹងដែរ ប៉ុន្តែគាត់ប្រឡងជាប់គ្រូ ។

ឡុងដានីៈ	តាថុចនឹង គាត់ប្រឡងជាប់គ្រូ?

ស៊ីនផែនៈ	ចា៎ស!ប្រឡងជាប់គ្រូ តែបងខ្ញុំវាធ្លាក់ ។ ប្រឡងជាមួយគ្នានឹង ដល់ពេលទៅប្រឡងបងខ្ញុំធ្លាក់ គាត់ជាប់ ។

ឡុងដានីៈ	ចុះតាថុច គាត់បានធ្វើគ្រូបង្រៀននៅឯណា?

ស៊ីនផែនៈ	គ្រូបង្រៀន ។

ឡុងដានីៈ	បង្រៀននៅឯណាទៅ?

ស៊ីនផែនៈ	បង្រៀននៅបោះព្រីងនឹង ។

ឡុងដានីៈ	ចុះអ៊ីកាលជំនាន់នឹង ខាងជនជាតិវិញ ចិន ចាម វៀតណាមអីយ៉ាងមេ៉ចដែរ នៅតាមស្រុកភូមិយើង?

ស៊ីនផែនៈ អឺ!ចិន ចាម ដូចជាគ្មានទេ មានតែវៀតណាម ចាប់គ្មានសល់ទេ យកទៅអស់ ហើយស្រីប្រុសអីយកទៅ ។ អើ!យកតែសារក្រោយទេ បើកាលសារមុនគ្មានយកទៅណាទេ ទុកនៅនឹងទាំងអស់ធ្វើការជាមួយយើងដែរ រកស៊ីលក់ដូរធម្មតាទៅណា ។

ឡុងដានីៈ គេចាប់យកវៀតណាមទៅនៅឆ្នាំណា គេចាប់ផ្តើមចាប់?

ស៊ីនផែនៈ ឆ្នាំៗគឺឆ្នាំ៧៧ ។

ឡុងដានីៈ កាលនឹងអ៊ំដឹងថា មានព្រឹត្តិការណ៍អីបានគេចាប់ផ្តើមយកវៀតណាមពីឆ្នាំ៧៧?

ស៊ីនផែនៈ កាលនឹងដែលចាប់យកទៅៗសម្លាប់ពីឆ្នាំ៧៧មកហើយ...។

ឡុងដានីៈ ដឹងថាហេតុអីបានជាគេចាប់កាលនៅឆ្នាំ៧៧?

ស៊ីនផែនៈ មិនដឹងដែរ កាលនឹងខ្ញុំមិនដឹងដែរ ។

ឡុងដានីៈ ចុះអើ!អ៊ំមាននៅចាំថាគ្រួសារវៀតណាម ណាខ្លះដែលគេត្រូវយកចាប់ទៅ បើតាមអ៊ំចាំ អ៊ំស្គាល់ក្រុមគ្រួសារ?

ស៊ីនផែនៈ ...អាយុន ហើយស្អីទេច្រើនណាស់ ។ ប៉ុននិយាយពីចិនៗសឹងនៅរស់ ។

ឡុងដានីៈ ចិននៅរស់វិញ?

ស៊ីនផែនៈ ចា៎ស! វៀតណាមមិនបានទេ អ្នករត់ចូលទៅទាន់ៗ ទៅមិនទាន់ស្លាប់អស់តែម្តង ។

ឡុងដានីៈ ចុះមានខ្មែរយើង មានរត់ទៅខាងវៀតណាមទេ?

ស៊ីនផែនៈ មានគេខ្លះទៅអញ្ចឹងដែរ គេទៅរួចអញ្ចឹងទៅ ខ្លះគេទៅមិនរួចគ្នាងាប់ ដូចគ្រួសារខ្ញុំបើសិនជាទៅបាត់ហើយ តែដល់នេះមកពីគេថាមិនអី អាងថាមិនអី មិនដល់ថ្នាក់គេយកទៅសម្លាប់អញ្ចឹងផង គ្មានដឹងខ្លួនអញ្ចឹង បើសិនជាដឹងខ្លួននៅស្រុកយួនបាត់ហើយមិនដឹងសន្និដ្ឋានថាម៉េច បើវាមិនអីវាមិនដែលដល់យកទៅសម្លាប់បន្ទឹដាក់គុកដាក់អីអញ្ចឹងណា គាត់ទេជាអ្នកនិយាយប្រាប់ខ្ញុំថា«វាទៅវាមិនមែនអីទេ អញខំជាប់គុក៤-១០-២០ឆ្នាំអញរស់មកវិញហើយ»ថាអញ្ចឹងណា ប្រាប់ខ្ញុំអញ្ចឹង ។

ឡុងដានីៈ ចុះអ៊ំនៅឆ្ងាយពីព្រំដែនវៀតណាម?

ស៊ីនផែនៈ ឆ្ងាយដែរ ។

ឡុងដានីៈ ប៉ុន្មានគីឡូ?

ស៊ីនផែនៈ មិនដឹងប៉ុន្មានគីឡូទេ ខ្ញុំដឹងថា...ឆ្ងាយទៅទៀត ។

ឡុងដានី៖ ចុះអ៊ីដូចខាងវៀតណាមដែលគេយកទៅនឹង វៀតណាមយកប្ដីខ្មែរ អីក៏ខ្មែរយកប្រពន្ធវៀតណាមៗយកប្រពន្ធខ្មែរ កាលនឹងគេយកទាំងខ្មែរទាំងវៀតណាម?

ស៊ីនផែន៖ អត់ទេ!ដូចថាវៀតណាមម្នាងអញ្ចឹងណា បើអ្នកយកខ្មែរយើង...។

ឡុងដានី៖ អ៊ំៗថាម៉េចបើមិញ បើប្រពន្ធខ្មែរប្ដីវៀតណាម គេអត់ទុកកូនទេ?

ស៊ីនផែន៖ គេអត់ទុកទេ គេយកទៅទាំងអស់។

ឡុងដានី៖ គេថាម៉េច?

ស៊ីនផែន៖ តែប្ដីខ្មែរសុទ្ធអញ្ចឹងយកប្រពន្ធវៀតណាម ហើយដល់វៀតណាមមានកូនអញ្ចឹង គេយកប្រពន្ធនិងកូន យកទៅសម្លាប់ចោលអស់ហើយ អត់ទុកទេ។

ឡុងដានី៖ គេថាអី?

ស៊ីនផែន៖ មិនដឹងរបៀបម៉េចគេ គេយកអញ្ចឹង តែបើប្ដីទុក។

ឡុងដានី៖ អ៊ំនិយាយមិញ ថាមេបំបៅកូន?

ស៊ីនផែន៖ គេថាមេបំបៅកូន ថាវៀតណាមនឹងដូចថាមេបំបៅកូន ហើយគេសុំទុកអត់ទុកទេ គេយកទៅហើយ បើប្ដីវៀតណាមហើយប្រពន្ធខ្មែរអានឹងត្រូវនៅហើយ ប្រពន្ធនឹងណា បើប្រពន្ធខ្មែរ គេយកតែប្ដីទៅទេណា កូនមិនយកទេ។

ឡុងដានី៖ អ៊ំនៅស្រុកភូមិនឹងរហូត ទល់បែកឆ្នាំ៧៩ឬក៏យ៉ាងម៉េចដែរ?

ស៊ីនផែន៖ ខ្ញុំនៅតាំងពីខ្ញុំកើតមកៗនៅភូមិនឹង។

ឡុងដានី៖ កាលជំនាន់ប៉ុលពត កាលពី៧៥-៧៩ គេអត់មានជម្លៀសអ៊ំទេ?

ស៊ីនផែន៖ ចាស!អត់មានទេ។

ឡុងដានី៖ នៅនឹងទល់តែបែកឆ្នាំ៧៩?

ស៊ីនផែន៖ នៅទាល់តែបែកនៅនឹង។

ឡុងដានី៖ ចំពោះកាលជំនាន់ប៉ុលពតនឹង វត្តអារាមនឹងគេយកទៅធ្វើអីដែរ?

ស៊ីនផែន៖ វត្តនឹងនៅសល់តែវិហារ គេយកទៅធ្វើរោងបាយ យកទៅធ្វើស្អីនៅក្នុងវិហារ គេបោកស្រូវ ជាន់ស្រូវអញ្ចឹងណា ដាក់ក្នុងនឹង ធ្វើរោងបាយវត្តនឹងមួយ ហើយកើតនោះមួយពីរ។

ឡុងដានី៖ ចុះលោកអីមានទេ?

ស៊ីនផែន៖ លោកមិនមានទេ សឹកអស់ហើយ។

ឡុងដានី៖ ចុះព្រះអង្គក្នុងវិហារ?

ស៊ីនផែនៈ ខ្លះគេយកទៅវាយចោលតែម្ដង ។

ឡុងដានីៈ គេយកទៅវាយចោល?

ស៊ីនផែនៈ ចាស!

ឡុងដានីៈ ម៉េចអ៊ីដឹងថា មូលហេតុអីបានគេយកព្រះអង្គ វិហារយកទៅវាយចោល?

ស៊ីនផែនៈ ខ្ញុំក៏មិនសូវដឹងដែរនឹងណា ប៉ុន្ដែគ្រង់ថានេះ គេថាយកទៅវាយចោលឲ្យអស់យកទៅដាក់នៅក្នុងអន្លង់អីទៅណា យកបំបាត់ចោលអស់ទៅ ខ្ញុំដឹងអញ្ចឹង គ្រង់ថារឿងអីៗ ហេតុអី ហេតុអី មូលហេតុអីយ៉ាងម៉េច ខ្ញុំមិនសូវដឹងដែរ ។

ឡុងដានីៈ អានឹងដូចថាគ្រួសាររបស់អ៊ំ គាត់មានដែលនិយាយពីគោលការណ៍របស់ខាង?

ស៊ីនផែនៈ អញ្ចឹងៗនឹង!មិនដែលនិយាយមិនដែលទេ គាត់មិនដែលនិយាយស្អីទេ តែបើតាមចិត្តគាត់នឹងមិនឲ្យធ្វើទេណាអញ្ចឹងៗ ប៉ុន្ដែមានគេអ្នកថ្នាក់លើណាៗ មិនដឹងទេណាអ្នកមកឲ្យធ្វើអញ្ចឹងៗទៅណា ហើយគាត់ចេះតែតាមគេទៅណា គេឲ្យធ្វើអញ្ចឹងទៅណា ហើយភូមិអីវ៉ាន់ទៅណា ប្រាប់ភូមិប្រាប់អីទៅណា គេធ្វើទៅណា ហើយខ្ញុំក៏មិនសូវបានដឹងដែរ ។

ឡុងដានីៈ អ៊ំនិយាយប្រាប់ថា អ្នកប្រាប់ឲ្យធ្វើ អ៊ំមានដឹងថាថ្នាក់លើខាងណាទេ?

ស៊ីនផែនៈ មិនដឹងខាងណាទេ ខ្ញុំមិនដឹងដែរ អត់ស្គាល់គេផង ។ តែនេះផែនការវាសុទ្ធតែមានហើយណា មានមកពីលើពីណាពីណោមកហើយណា បានគេហ៊ានធ្វើអញ្ចឹង ។ តែនេះវាទូទៅគ្រប់វត្ដ វាអស់រលីងរលុតទៅហើយណា ទៅតាមអញ្ចឹងតែម្ដងទៅណា អានេះខ្ញុំមិនជឿគេទេ ។

ឡុងដានីៈ ខ្ញុំដូចជាអស់សំណួរហើយ អញ្ចឹងអ៊ំមានអីចង់បញ្ជាក់អ៊ីបន្ថែម អ៊ីដែលពួកខ្ញុំអត់ទាន់បានសួរអ៊ំពីរឿងរ៉ាវក្នុងសម័យខ្មែរក្រហមទៀតដែរឬអត់?

ស៊ីនផែនៈ ខ្ញុំចង់សួរប៉ុននេះដែរ ដែលស្រាវជ្រាវនឹងយកទៅមូលហេតុយ៉ាងម៉េចៗ បានខំស្រាវជ្រាវ?

ឡុងដានីៈ ដូចពួកខ្ញុំបានជម្រាបអ៊ំកាលពីមុនសម្ភាសន៍នឹងថា ពួកខ្ញុំជាអ្នកស្រាវជ្រាវពីប្រវត្តិសាស្ត្រពីរបបខ្មែរក្រហម ពួកខ្ញុំមកជួបអ៊ំសួរនាំអ៊ំទាក់ទងពីរឿងបងរបស់អ៊ំ អ៊ីជីវិតរបស់អ៊ំនៅសម័យខ្មែរក្រហមនឹង គឺដើម្បីចងក្រងទុកជាប្រវត្តិសាស្ត្រពីរបបខ្មែរក្រហមនឹងណា ។

ស៊ីនផែនៈ ចាស!

ឡុងដានី៖ អ៊ំមានចង់សួរពួកខ្ញុំអីទៀតអត់?

ស៊ីនផែន៖ មិនដឹងសួរពីស្អីទេ ។

ឡុងដានី៖ បាទ! អញ្ចឹងខ្ញុំសូមអរគុណអ៊ំច្រើន ។